# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៧-៤-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៤១២/៣៣៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **ហ័ង ស៊ូ** (HUANG XU) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តក្វាងដុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះ ជា **អាន ជី** (ANN JI) ៤១៣៩

១៧-៤-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៤១២/៣៣៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជឿង ស៊ុង** (JEONG SUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ជា សំណាង** (CHEA SAMNANG) ៤១៤០

១៩-៤-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៤១២/៣៦២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ម៉ាទីន រ៉ូបឺត អេឌ្រៀន លូអ៊ីស ដេសូតេស្ស** (MARTIN, ROBERT, ADRIEN, LOUIS DESAUTELS) ជនជាតិកាណាដា សញ្ជាតិបារាំង កើតនៅ QUEBEC ប្រទេសកាណាដា ដោយប្តូរឈ្មោះ ជា **ម៉ាទីន ដេសូតេស្ស** (MARTIN DESAUTELS) ៤១៤១

១៩-៤-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៤១២/៣៦៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ យូយ៉ាង** (LIU YUGANG) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តក្វាងដុង សាធារណរដ្ឋប្រជាមានិតចិន ៤១៤២

២៦-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៨២ ស្តីពី ការតែងតាំងឯកឧត្តម **គង់ សម្បត្តិ** ជាទីប្រឹក្សា អមក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ៤១៤៣

២៦-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៩០ ស្តីពី ការតែងតាំង ឯកឧត្តម **ប៉ត់ ទិជិត** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៤១៤៤

២៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៥០៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន ០២ រូប ៤១៤៥

២៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៥០៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា អស់លោក ជាមន្ត្រីរាជការ និង សប្បុរសជន ចំនួន ១៩ រូប ៤១៤៦

២៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៥០៨ ស្តីពី ការតែងតាំង ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ ចំនួន ០៤ រូប ៤១៤៧

៣០-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៥០៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ព្រះតេជគុណ យ៉ាន់ ថាត់ ៤១៤៨

៣០-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៥១០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ១៥ រូប ៤១៤៩

៣០-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៥១១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ ព្រះគ្រូបញ្ញាបទីបោ ម៉ូ ពិសិដ្ឋ ៤១៥០

៣០-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៥១៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ មន្ត្រីរាជការ ចំនួន ០២ រូប ៤១៥១

៣០-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៥១៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ០៤ រូប ៤១៥២

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥១៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ចំនួន ២៤ រូប ៤១៥៣

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥១៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០២ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងអប់រំ យុវជន និង កីឡា ៤១៥៤

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥១៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៥ រូប ៤១៥៦

០២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥១៩ ស្តីពី ការតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ទោ ជា សុគន្ធា ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន និងត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ ជា សុគន្ធា នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៤១៥៧

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ


០៧-៦-២០១២ -អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្ដីពី ការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៤១៥៨

០៧-៦-២០១២ -អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្ដីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៤១៦៧

០៧-៦-២០១២ -អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្ដីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៤១៦៩

០៧-៦-២០១២ -អនុក្រឹត្យលេខ ៨០ អនក្រ.បក ស្ដីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៤១៧១

០៧-៦-២០១២ -អនុក្រឹត្យលេខ ៨១ អនក្រ.បក ស្ដីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៤១៧៣

៣០-៥-២០១២ -អនុក្រឹត្យលេខ ៦៣២ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤១៧៥

០៤-៦-២០១២ -អនុក្រឹត្យលេខ ៦៣៧ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤១៧៦

០៤-៦-២០១២ -អនុក្រឹត្យលេខ ៦៣៨ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៤១៧៧

០៤-៦-២០១២ -អនុក្រឹត្យលេខ ៦៣៩ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤១៧៨

០៤-៦-២០១២ -អនុក្រឹត្យលេខ ៦៤០ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤១៧៩

០៤-៦-២០១២ -អនុក្រឹត្យលេខ ៦៤១ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៨១

០៤-៦-២០១២ -អនុក្រឹត្យលេខ ៦៤២ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤១៨២

០៤-៦-២០១២ -អនុក្រឹត្យលេខ ៦៤៣ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៨៤

០៤-៦-២០១២ -អនុក្រឹត្យលេខ ៦៤៤ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤១៨៥

០៥-៦-២០១២ -អនុក្រឹត្យលេខ ៦៤៥ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤១៨៦

០៥-៦-២០១២ -អនុក្រឹត្យលេខ ៦៤៦ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤១៨៧

០៥-៦-២០១២ -អនុក្រឹត្យលេខ ៦៤៧ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៨៨

០៥-៦-២០១២ -អនុក្រឹត្យលេខ ៦៤៨ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤១៨៩

០៥-៦-២០១២ -អនុក្រឹត្យលេខ ៦៤៩ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៩០

០៥-៦-២០១២ -អនុក្រឹត្យលេខ ៦៥០ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤១៩១

០៥-៦-២០១២ -អនុក្រឹត្យលេខ ៦៥១ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៤១៩២

០៥-៦-២០១២ -អនុក្រឹត្យលេខ ៦៥២ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៤១៩៣

០៦-៦-២០១២ -អនុក្រឹត្យលេខ ៦៥៣ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៤១៩៥

០៦-៦-២០១២ -អនុក្រឹត្យលេខ ៦៥៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤១៩៦

## ២-សារាចរណែនាំ

០៨-៦-២០១២ -សារាចរណែនាំលេខ ០៦ សរណន ស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ៤១៩៧

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-៤-២០១២ -ប្រកាសលេខ ៤១៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឥណ្ឌូចិន ហ្គាវ៉ិន្ត (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៤២២០

១៨-៤-២០១២ -ប្រកាសលេខ ៤១៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដាប់ប៊ែល យូ. អ៊ី.ជី.ស៊ី មេនូហ្វេកឈើរីង លីមីធីត បង្កើតរោងចក្រ ផលិតកាបូប, ស្រោមដៃកីឡា, មួកកីឡា ៤២២៤

២៣-៤-២០១២ -ប្រកាសលេខ ៤៣៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយស៍ មីល ខមផ្លេកស៍ បង្កើតរោងចក្រ ផលិតអង្ករ ៤២២៨

២៣-៤-២០១២ -ប្រកាសលេខ ៤៣៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ៊ូត ហ្វ័រវើត (ខេមបូឌា) សកខ៍ បង្កើតរោងចក្រ ផលិតស្រោមជើង ៤២៣២

២៣-៤-២០១២ -ប្រកាសលេខ ៧៣៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ូរ៉ូហ្វូជី (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ ផលិតថង់ពីប្លាស្ទិក, សម្ភារៈវេចខ្ចប់ពីប្លាស្ទិក ៤២៣៦

## ២-ទីស្តីការក្រសួងពាណិជ្ជកម្ម

០៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១២២២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូថល ណាញ អិលធីឌី** ៤២៤០

០៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៤៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គង់ ពៅ ពិសិដ្ឋ ស៊ីវិលស្រ្គិន ព្រីនធីង** ៤២៤២

០៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៤៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីខូ-ឡូយអីល អយល៍ ស៊ីឌីស** ៤២៤៤

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថូ ពេជ្រ ឌីវេឡុបមេន** ៤២៤៦

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា ប៊ីយូធី សេនធ័រ** ៤២៤៨

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៥០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេសាន គីរី យ៉ញូ ស្តុត អ៊ិនវេសមេន គ្រុបខឹប** ៤២៥០

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៥១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថ៉ាន ស្តារ គ្រុបខឹប** ៤២៥២

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៦០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ការិយាល័យតំណាងពាណិជ្ជកម ក្រុមហ៊ុន **ខនិត រីស៊ើច អេសឌីអិន. ប៊ីអេចឌី. (ខេមបូឌា)** ៤២៥៤

០៩-៣-២០១១ -លិខិតបញ្ជាក់លេខ ១២៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អេច អ៊ីខ អាសូស៊ីអេត គីធីអ៊ី អិលធីឌី** ៤២៥៥

# ព្រះរាជក្រឹត្យ

នស/រកត/០៤១២/៣៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **ហ៊័ង ស៊ូ** (HUANG XU) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៨២ នៅខេត្តក្វាងដុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **អាន ជី** (ANN JI)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣កល.១២០៤.៣៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២

លេខ:៣៣៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៤១២/៣៣៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជឿង ស៊ុង** (JEONG SUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៦០ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ជា សំណាង** (CHEA SAMNANG)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៩. ១២០៤. ៣៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២

លេខៈ ៣៣៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible]៧ ខែមេសា ឆ្នាំ២០១២
អគ្គលេខា[illegible]ទីរាជរដ្ឋាភិបាល
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១២/៣៦២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ម៉ាទីន រ៉ូបឺត អេឌ្រៀន លូអ៊ីស ដេសូតេស្ស** (MARTIN, ROBERT, ADRIEN, LOUIS DESAUTELS) ជនជាតិកាណាដា សញ្ជាតិបារាំង កើតថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៦៩ នៅ QUEBEC ប្រទេសកាណាដា ដោយប្តូរឈ្មោះជា **ម៉ាទីន ដេសូតេស្ស** ( MARTIN DESAUTELS)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៩.១៤០៤.៣៦៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០១២

លេខ: ៣៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ[illegible] ឆ្នាំ២០១២
អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១២/៣៦៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ យូហ្គាង** (LIU YUGANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៦៥ នៅខេត្តខ្វាងដុង សាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ករ.១២០៤.៣៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២

លេខៈ ៣៣៥ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible]៤ ខែ[illegible] ឆ្នាំ២០១២
អគ្គលេខាធិការរង[illegible]រាជរដ្ឋាភិបាល

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្តម **គង់ សម្បត្តិ** ជាទីប្រឹក្សាអមក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៦.១២០៥.៤៥៥

លេខ: ៥១២ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
**សយ សុខា**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៩០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ប៉ត់ ចិជិត** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៧.១២០៥.៤៩៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤៩៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃ ០៦ ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៥០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១ | លោកជំទាវ **លន់ សាឌី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ២ | ឯកឧត្តម **ម៉ែន សើវុឌ្ឍ** | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១២០៥.៥១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤៥៨ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

សុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៥០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

ឯកឧត្តម ឧកញ៉ា អស់លោក ជាមន្ត្រីរាជការ និងសប្បុរសជនចំនួន ១៩រូប
ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិមាតុភូមិ

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម វ៉ែត្ត មុន្នី

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ហ៊ូត ឫទ្ធី  ២- ឯកឧត្តម ឆាយ សាខុធ

៣- ឧកញ៉ា ជា សំណាង  ៤- លោក សុខ ម៉ៅ

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- ឯកឧត្តមឧកញ៉ា ខេង ច័ន្ទា  ២- លោក ចិន សាម៉ន

៣- លោក ម៉េង ហ៊ាង

ឃ- គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :

១- វរសេនីយ៍ឯក សោម ជោគ អត្ត.០០១៣៦៩២  ២- វរសេនីយ៍ឯក ជា នុសិទ្ធ អត្ត.០០៨៥៧៥

៣- វរសេនីយ៍ឯក ផ្លង គឹមចណ្ណៈ អត្ត.០០២១៨៥  ៤- វរសេនីយ៍ទោ ឡុន ភក្តី អត្ត.០២៤៦៥១

ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ ជា ចំរើន  ២- វរសេនីយ៍ទោ អែល ណន អត្ត.០០១៧៥៧

៣- អនុសេនីយ៍ឯក ចិន ខុធ អត្ត.០៤៣៤៩២  ៤- អនុសេនីយ៍ឯក សួស សុខចណ្ណា អត្ត.០៣៦២៧៦

៥- អនុសេនីយ៍ត្រី ផាន់ ប៊ុនហួត អត្ត.១៧៤៧៤  ៦- លោក អៀង សុខឃីម

៧- លោក គង់ គុលធីរៈ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
**នរោត្តម សីហមុនី**

០៦១២.១២០៥.៥១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤៤២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល

ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៥០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឆេត សំអាន** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **ស៊ុយ ចំនួណារិទ្ធ** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៣- ឯកឧត្តម **ខៀវ សុផល** មានឋានៈស្មើ **រដ្ឋលេខាធិការ**

៤- ឯកឧត្តម **សេង ចំរើន** មានឋានៈស្មើ **រដ្ឋលេខាធិការ**

**មាត្រា ២ :** លេខរៀងទី ២៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣០០ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៩៣.១២០៥.៥១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៤៩៧ ប.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៥០៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

**ចំពោះ**

**ព្រះតេជគុណ យ៉ាន់ ចាត់**

បានបរិច្ចាគធនធានផ្ទាល់ ចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា
និងសង្គមជាតិ ស្ថិតនៅក្នុងវត្តអង្គតាមិញ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៧.១២០៥.៥១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៥០៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**
**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៥១០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រទានព្រះរាជទាន

**ចំពោះ**

សប្បុរសជន ចំនួន១៥រូប មានគុណបំណាច់ខ្ពស់និងស្នាដៃល្អប្រសើរ ក្នុងការចូលរួមកសាងសមិទ្ធផលនានា នៅវត្តប្រាសាទ ភូមិត្រពាំងសំរិទ្ធិ សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ សម្រេចបានលទ្ធផលគួរជាទីមោទនៈ

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

ឧកញ៉ា ឆោំ សួន

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

លោក នួន ចំនួរិទ្ធ

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១-ឧកញ៉ា ជា គ្រី
២-លោកស្រី ខៀវ លក្ខិណា
៣-លោកជំទាវ ហាក់ ស្រីឌុច
៤-លោកជំទាវ ទ្រាក់ សុខា

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១-លោក តិន សុភារក្ស
២-លោក នាង វណ្ណា
៣-លោក ខាន់ វណ្ណៈ
៤-លោក ឃុន រ៉ាន់
៥-លោក ទ្រាក់ សូម៉េត
៦-លោក ដួង បូលីន
៧-លោក ប៊ិន អួន
៨-លោក ម៉ុក ឃួត
៩-លោក ចាំច់ សុឈា

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៣១៩៧.១២០៥.៥១៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

លេខ:៤៨៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៥១១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

**ចំពោះ**

**ព្រះគ្រូបញ្ញាបទីបោ ម៉ុំ ពិសិដ្ឋ**

មានព្រះគុណបំណាច់ ក្នុងការដឹកនាំកសាង ព្រះវិហារ និងសមិទ្ធផលនានា
នៅវត្តសាមគ្គីគិរីសំរិទ្ធ ខេត្តប៉ៃលិន សម្រេចបានលទ្ធផលល្អប្រសើរ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៤.១២០៥.៥១៧

លេខៈ ៥០៧ ច.ល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២
អគ្គលេខា[illegible]ការរង[illegible]រាជរដ្ឋាភិបាល

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៥១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**ចំពោះ**

មន្ត្រីរាជការ ចំនួន ០២រូប នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានស្នាដៃល្អ
ក្នុងការបំពេញភារកិច្ច លើវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ទទួលបានលទ្ធផលល្អប្រសើរ

**នូវ**

## គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

១-លោក សុក ចៅ
២-លោក ផ្លុង តូម៉ា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤.១២០៥.៥២០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៥០៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរង [illegible] រាជរដ្ឋាភិបាល
សិយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៥១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការ ចំនួន០៤រូប មានគុណបំណាច់ និងស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ដោយបានខិតខំយ៉ាងសកម្មក្នុងការអភិវឌ្ឍខេត្តបន្ទាយមានជ័យ ទទួលបានលទ្ធផលល្អប្រសើរ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-លោក លី សារី

២-លោក អ៊ុក កែវរតនៈ

៣-លោក ឥន្ទ សុចិត្រ

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

លោក ចាន់ សារ៉ា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧១៧.១២០៥.៥២១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤៨៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ២៤រូប មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ពិសេសលើវិស័យសាធារណការ និងដឹកជញ្ជូន នៅព្រះរាជាណាចក្រកម្ពុជា

**នូវ**

**ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ស៊ុយ សាន | ១១-លោក | ឈឹម សំបូរ |
| ២-ឯកឧត្តម | សុខ ស៊ុនលីន | ១២-លោក | កាង ម៉េងហាក់ |
| ៣-ឯកឧត្តម | ឈុប ហេង | ១៣-លោក | គឹម សុវណ្ណ |
| ៤-ឯកឧត្តម | នួន ចំរុង | ១៤-លោក | កែវ ពៅ |
| ៥-លោក | ម៉ឹង យូឡេង | ១៥-លោក | ស្រេង ស្រស់ |
| ៦-លោក | ខៀវ អំណាត់ | ១៦-លោក | សូ សំណាង |
| ៧-លោក | សុខ ស្រ៊ុន | ១៧-លោក | សរ គឹមណាត |
| ៨-លោក | ឆាន់ សំអាន | ១៨-លោក | គី ចរិទ្ធ |
| ៩-លោក | អ៊ុំ អ៊ួក | ១៩-លោក | ម៉ម នួច |
| ១០-លោក | ឡុង សាន | ២០-លោក | សំ សាឆុន |

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ចាំស៊ឹម សុរិយា | ៣-លោក | ម៉ៅ ធនារក្ស |
| ២-ឯកឧត្តម | គឹម សាន់ | ៤-លោក | ម៉ឺន គឹម |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពាស.១២០៦.៥២២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៥០០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការ [illegible] រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម ០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ ៖** ត្រូវបានដំឡើងឋានន្តរសក្តិជូនមន្ត្រីរាជការចំនួន ០២ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ៖

| ល.រ | នាម និង គោត្តនាម | ភេទ | ឋានន្តរសក្តិ និង ថ្នាក់ចាស់ | ឋានន្តរសក្តិ និង ថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| | **ចោង ប៊ុរ៉ាន់** | ប | ពី វរមន្ត្រី ថ្នាក់លេខ ២ | ទៅ ឧត្តមមន្ត្រី ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

| | | | | |
|---|---|---|---|---|
| ២ | **ឡោ សុជាតិ** | ប | ពី វរមន្ត្រី ថ្នាក់លេខ ៥ | ទៅ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា ២ ៖** ត្រូវបានដំឡើងឋានន្តរសក្តិជូនមន្ត្រីរាជការចំនួន ០១ រូប ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមាននាមខាងក្រោម ៖

| ល.រ | នាម និង គោត្តនាម | ភេទ | ឋានន្តរសក្តិ និង ថ្នាក់ចាស់ | ឋានន្តរសក្តិ និង ថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **អ៊ុក ឌុន** | ប | ពី គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | ទៅ គ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែពិសេស ថ្នាក់លេខ ៦ |

**មាត្រា ៣ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ ៖** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ ៖** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.០៦១២.៥២៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២*

លេខ: ៥១៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន០៥រូប មានស្នាព្រះហស្ត ស្នាដៃនិងគុណបំណាច់ចំពោះជាតិនិងសាសនា ដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនានិងសង្គមជាតិ ស្ថិតនៅក្នុងវត្តញាណរង្សី សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១-លោក ម៉ាត ចន្ថា
២-លោក សួន សេដ្ឋា
៣-លោក ម៉ាក ចាន់តារា

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

ព្រះសុវណ្ណជោតិ ខឹម សម្បត្តិ

**គ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា**

ឯកឧត្តម ឆាន់ ចន្ទ្រា

៣៣៣-១២០៦-៥២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៥០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៧៧៨ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ ជា សុគន្ធា អត្តលេខ ០១៥២៨ ជា ទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយបន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ ជា សុគន្ធា អត្តលេខ ០១៥២៨ នាយនគរបាលជាតិជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

រាជ.១២០៦.៥៤៥

លេខ:៤៩៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការ...ទីស្តីការគណៈរដ្ឋមន្ត្រី... រាជរដ្ឋាភិបាល
...សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៧. អនក្រ. បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និង គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ៖

- **ផែនការរៀបចំដែនដីថ្នាក់ខេត្ត** ជាផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រ តម្រង់ទិសនៃការប្រើប្រាស់ដីនិងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្តានុពលនៃ ភូមិសាស្ត្រនិងតំបន់នីមួយៗក្នុងក្របខ័ណ្ឌថ្នាក់ខេត្ត។
- **ប្លង់គោលប្រើប្រាស់ដីថ្នាក់រាជធានី ថ្នាក់ក្រុង ថ្នាក់ស្រុក ថ្នាក់ខណ្ឌ** ជាផែនការកំណត់ ចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍផ្នែករូបវន្ត និងកំណត់អំពីប្រភេទដី ព្រមទាំងបង្ហាញអំពីបណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍សំខាន់ៗ និងការធ្វើ សមាហរណកម្មក្របខ័ណ្ឌថ្នាក់រាជធានី ថ្នាក់ក្រុង ស្រុក ខណ្ឌ ទៅនឹងថ្នាក់តំបន់ និង ថ្នាក់ជាតិ។
- **ផែនការប្រើប្រាស់ដីថ្នាក់រាជធានី ថ្នាក់ក្រុង** ជាផែនការលំអិតចេញពីប្លង់គោលដែល កំណត់អំពីប្រភេទនៃការប្រើប្រាស់ដីនៅតំបន់នីមួយៗកំណត់អំពីបទប្បញ្ញត្តិប្រើប្រាស់ ដី ការអភិវឌ្ឍដី និងលទ្ធភាពនៃការសាងសង់ក្នុងតំបន់នីមួយៗ ព្រមទាំងបង្ហាញអំពី ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនិងការធ្វើសមាហរណកម្មទៅថ្នាក់តំបន់និងថ្នាក់ជាតិ។

## ជំពូកទី២
## សមាសភាព តួនាទី និងភារកិច្ចរបស់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត

**មាត្រា ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ០១រូប | អនុប្រធាន |
| - ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| - តំណាងក្រុមប្រឹក្សារាជធានី ខេត្ត ០១រូប | សមាជិក |
| - ប្រធានមន្ទីរនិងប្រធានអង្គភាពពាក់ព័ន្ធនានាជុំវិញរាជធានី ខេត្ត | សមាជិក |
| - នាយករដ្ឋបាល សាលារាជធានី ខេត្ត | សមាជិក |
| - អភិបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ | សមាជិក |

- តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត ០២រូប សមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
របស់ក្រុមប្រឹក្សារាជធានី ខេត្ត ០១រូប សមាជិក។

តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត ០២រូប ត្រូវចាត់តាំងឡើងដោយគណៈកម្មាធិការប្រតិបត្តិនៃសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត។ តំណាងទាំងពីររូបនេះត្រូវមានស្ត្រីយ៉ាងតិចមួយរូប។

ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត មានលេខាធិការដ្ឋានមួយជាសេនាធិការ ដឹកនាំដោយអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងមានសមាសភាពមកពីសាលារាជធានី ខេត្ត និងតំណាងមន្ទីរនិងអង្គភាពពាក់ព័ន្ធជុំវិញរាជធានី ខេត្ត ជាសមាជិក។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម រាជធានី ខេត្ត ត្រូវស្នើសុំការសម្រេចពីក្រុមប្រឹក្សារាជធានី ខេត្ត អំពីសមាសភាពនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ។

## ផ្នែកទី១ : ថ្នាក់រាជធានី

**មាត្រា ៤.-**

នៅថ្នាក់រាជធានី មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ត្រូវផ្តួចផ្តើមនិងរៀបចំឡើងដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី និងសម្របសម្រួលដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ(**គ.ជ.ន.ជ.**)។ ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ត្រូវសម្រេចដាក់ឲ្យប្រើប្រាស់ដោយអនុក្រឹត្យ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនេះ ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០(ម្ភៃ)ឆ្នាំខាងមុខ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

នីតិវិធីលំអិតស្តីពីការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ន.ជ.**។

**មាត្រា ៥.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ផ្តួចផ្តើមនិងរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ និងផែនការប្រើប្រាស់ដីថ្នាក់សង្កាត់ ឲ្យមានប្រសិទ្ធភាព និងចំទិសដៅ
- ដឹកនាំពិគ្រោះយោបល់ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ក្រុមប្រឹក្សា និងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី

- ពិនិត្យនិងផ្តល់យោបល់ជូនក្រុមប្រឹក្សារាជធានី លើប្លង់គោលប្រើប្រាស់ដី និង ផែនការប្រើប្រាស់ដីថ្នាក់រាជធានី លើប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ និងផែន ការប្រើប្រាស់ដីថ្នាក់សង្កាត់
- ស្នើសុំការយល់ព្រមពី **គ.ជ.ន.ជ.** ចំពោះប្លង់គោលប្រើប្រាស់ដីនិងផែនការ ប្រើប្រាស់ដីថ្នាក់រាជធានី
- ស្នើសុំការសម្រេចពី **គ.ជ.ន.ជ.** លើប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- កែសម្រួលនិងធ្វើបច្ចុប្បន្នកម្ម លើប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ ដីថ្នាក់រាជធានី ទៅតាមរយៈពេលកំណត់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំជូន **គ.ជ.ន.ជ.** អំពីលទ្ធផលនៃការអនុវត្ត ការងារ
- លើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់រៀបចំប្លង់គោលប្រើ ប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- បំពេញភារកិច្ចដែលពាក់ព័ន្ធនឹងការងាររៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការ ប្រើប្រាស់ដីថ្នាក់រាជធានី
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ន.ជ.**ប្រគល់ជូន។

## ផ្នែកទី២ : ថ្នាក់ខេត្ត

**មាត្រា ៦.-**

នៅថ្នាក់ខេត្តមានផែនការរៀបចំដែនដីថ្នាក់ខេត្ត។

ផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវផ្តួចផ្តើមនិងរៀបចំឡើងដោយគណៈកម្មាធិការរៀបចំ ដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត ដោយមានការឯកភាពពីក្រុមប្រឹក្សាខេត្ត។ ផែនការរៀបចំ ដែនដីថ្នាក់ខេត្ត ត្រូវសុំការយល់ព្រមពី **គ.ជ.ន.ជ.** និងសម្រេចដាក់ឲ្យប្រើប្រាស់ដោយអនុក្រឹត្យ។

ផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០(ម្ភៃ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

នីតិវិធីលំអិតស្តីពីការរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្តត្រូវកំណត់ដោយសេចក្តីសម្រេច របស់ប្រធាន **គ.ជ.ន.ជ.**។

**មាត្រា ៧.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្តមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ផ្តួចផ្តើមនិងរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្ត
- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តផែនការរៀបចំដែនដីថ្នាក់ខេត្ត ប្លង់គោល ប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក និងផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ឲ្យមានប្រសិទ្ធភាពនិងចំទិសដៅ
- ដឹកនាំពិគ្រោះយោបល់ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាព ពាក់ព័ន្ធក្នុងការរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្ត
- ពិនិត្យនិងផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្តលើផែនការរៀបចំដែនដីថ្នាក់ខេត្ត លើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង លើប្លង់គោលប្រើ ប្រាស់ដីថ្នាក់ស្រុក និងផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់

- ស្នើសុំការយល់ព្រមពី **គ.ជ.ន.ជ.**លើផែនការរៀបចំដែនដីថ្នាក់ខេត្ត
- ស្នើសុំការសម្រេចពី **គ.ជ.ន.ជ.**លើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងលើប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក
- ពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នកម្ម លើផែនការរៀបចំដែនដីថ្នាក់ខេត្តតាមរយៈពេលកំណត់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូន **គ.ជ.ន.ជ.**អំពីលទ្ធផលនៃសកម្មភាពការងារ
- លើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ខេត្ត
- បំពេញភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីក្នុងក្របខ័ណ្ឌថ្នាក់ខេត្ត
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ន.ជ.** ប្រគល់ជូន។

## ជំពូកទី៣
## សមាសភាព តួនាទី និងភារកិច្ចរបស់
## គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ

**មាត្រា ៨.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | ប្រធាន |
| - អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ០១រូប | អនុប្រធាន |
| - ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ | សមាជិកអចិន្ត្រៃយ៍ |
| - តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ០១រូប | សមាជិក |
| - នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | សមាជិក |
| - ប្រធានការិយាល័យនិងប្រធានអង្គភាពពាក់ព័ន្ធក្នុងក្រុង ស្រុក ខណ្ឌ | សមាជិក |
| - មេឃុំ ចៅសង្កាត់ទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌ | សមាជិក |
| - តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | សមាជិក |

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌមានក្រុមការងាររៀបចំដែនដីនិងនគរូបនីយកម្មមួយ ជាសេនាធិការ ដឹកនាំដោយអនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ និងមានសមាសភាពសាលាក្រុង ស្រុក ខណ្ឌ និងតំណាងការិយាល័យនិងអង្គភាពពាក់ព័ន្ធជុំវិញក្រុង ស្រុក ខណ្ឌជាសមាជិក។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវស្នើសុំការសម្រេចពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អំពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមការងារនេះ។

## ផ្នែកទី១ : ថ្នាក់ក្រុង

**មាត្រា ៩.-**

នៅថ្នាក់ក្រុង មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង។

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយសហមេត្រ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកស្រី **ហ្សាណែល ផ្លាំមើ** ជំនាញការជាន់ខ្ពស់ផ្នែកអភិបាលកិច្ច ធនាគារពិភពលោក ដែលបានជួយជ្រោមជ្រែងគាំទ្រក្នុងការអនុវត្តគម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ មានការវិវត្តល្អប្រសើរ ។

**មាត្រា ២** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១២*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ១ និងមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២រូប បំពេញក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោក **ឈឹម ភាន** ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៧ ជាអគ្គនាយករង ជំនួសលោក **ជាម ប៉េអា** ដែលបានទទួលមុខតំណែងថ្មី

២-លោក **សូស ច្រាន់ដា** ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៨ ជាអគ្គនាយករង ជំនួសលោក **ជាង ឡេងហួត** ដែលបានចូលនិវត្តន៍ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៦៥៣. អនក្រ-បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

### ស ម្រេ ច

**មាត្រា ១** : ត្រូវបានតែងតាំង លោក **រាត់ ស៊ិទ្ធ** ជាប្រធាននាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន នៃក្រសួងបរិស្ថាន។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ មិថុនា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦៥៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន០៣រូប នៃមន្ទីរអប់រំ យុវជននិងកីឡា រាជធានីភ្នំពេញ ដែលមានស្នាដៃល្អក្នុងការស្វែងរកសប្បុរសជនជួយកសាងអគារសិក្សា ០១ខ្នង ០២ជាន់ ជូនដល់អនុវិទ្យាល័យវត្តដំបូកខ្ពស់ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | **គង់** | **កន្នីថា** | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌមានជ័យ |
| ២-លោក | **សោម** | **សុទ្ធ** | នាយកអនុវិទ្យាល័យ វត្តដំបូកខ្ពស់ |
| ៣-លោក | **សុន** | **សាន** | នាយកសាលាបឋមសិក្សា វត្តដំបូកខ្ពស់ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :..០៦...សរណន**

# សារាចរណែនាំ

# ស្តីពី

# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

## I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

១- សេដ្ឋកិច្ចកម្ពុជា ត្រូវបានទទួលរងនូវផលប៉ះពាល់នៃវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោកយ៉ាងធ្ងន់ធ្ងរចាប់ពីពាក់កណ្តាលឆ្នាំ២០០៨ ដែលធ្វើឱ្យកំណើនឆ្នាំ២០០៨ ធ្លាក់ចុះមកត្រឹម៦,៧% ធៀបនឹងកំណើនមធ្យមភាគ៣ឆ្នាំ ២០០៥-២០០៧ ដែលមានរហូតដល់១១,៤% និងបានធ្លាក់ដល់បាតនៅឆ្នាំ២០០៩ ដែលមានកំណើនស្ទើរតែស្មើសូន្យគឺត្រឹម០,១%។ ទន្ទឹមនឹងនេះ ក្នុងរយៈកាលពីរបីឆ្នាំចុងក្រោយនេះ កម្ពុជាក៏ត្រូវបានរងនូវវិបត្តិព្រំដែន គ្រោះធម្មជាតិ និងអត្រាអតិផរណាខ្ពស់ផងដែរ។ ទោះជាយ៉ាងនេះក្តី ដោយសារការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ គោលនយោបាយហិរញ្ញវត្ថុប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ និងគោលនយោបាយរូបិយវត្ថុដ៏សមស្រប គួបផ្សំនឹងការអប្បមាទជាប្រចាំ និងការដាក់ចេញនូវវិធានការប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា កម្ពុជាមិនត្រឹមតែអាចទប់ទល់នឹងវិបត្តិទាំងនោះបានដោយជោគជ័យប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យសេដ្ឋកិច្ចអាចងើបឡើងវិញបានយ៉ាងឆាប់រហ័សគឺពីកំណើនស្ទើរតែស្មើសូន្យនៅឆ្នាំ២០០៩ មក៦% នៅឆ្នាំ២០១០ និង៧,១% នៅឆ្នាំ២០១១ ហើយត្រូវបានព្យាករណ៍ថានឹងបន្តមានកំណើនប្រមាណ៧% នៅក្នុងឆ្នាំ២០១២ និង២០១៣ ខាងមុខនេះថែមទៀតផង ទោះជាស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅពុំទាន់មានភាពប្រាកដប្រជា និងនៅមានហានិភ័យខ្ពស់នៅឡើយក៏ដោយ ជាពិសេសសេដ្ឋកិច្ចនៅអឺរ៉ុប។

២- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ គឺស្ថិតក្នុងបរិការណ៍ដែលសេដ្ឋកិច្ចតំបន់ និងពិភពលោកបាន និងកំពុងងើបឡើងវិញចេញពីវិបត្តិក៏ពិតមែន តែនៅមានភាពមិនប្រាកដប្រជា និងហានិភ័យខ្ពស់នៅឡើយ មិនតែប៉ុណ្ណោះបណ្តាបញ្ហាប្រឈមថ្មីដែលបាន និងកំពុងកើតឡើងដូចជាសម្ពាធ នៃអត្រាអតិផរណាដែលបានរាលដាលចេញពីការឡើងថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារទៅដល់បណ្តាទំនិញដទៃទៀត និងការប្រែប្រួលនៃលំហូរមូលធនដែលអាចកើតឡើងដោយសារការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុជាដើម។ សម្រាប់ឆ្នាំ២០១៣ តាមការព្យាករកំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានក្នុងរង្វង់៧%។ វិស័យកសិកម្មនឹងបន្តរក្សាកំណើនក្នុងរង្វង់៣,៨% ក្នុងនោះផលិតផលស្រូវនឹងមានកំណើនប្រមាណ៤,៦% និង

ផលិតផលជលផល នឹងមានកំណើនប្រមាណ២,៥%។ ទន្ទឹមនឹងនេះ ថ្លៃនៃកសិផលមួយចំនួនបាន និងកំពុងបន្តមាននិន្នាការកើនឡើង ដូចជាស្រូវ ដំឡូងមី ស្វាយចន្ទី ពោត និងកៅស៊ូជាដើម ដែលជាសក្តានុពលរួមចំណែកជំរុញកំណើននៃវិស័យនេះ។ វិស័យឧស្សាហកម្មអាចនឹងមានកំណើន១០,៣% ក្នុងនោះផ្នែកវាយនភ័ណ្ឌអាចនឹងមានកំណើនប្រមាណ១១,៧% និងផ្នែកសំណង់អាចនឹងមានកំណើនប្រមាណ៥,៧%។ ទន្ទឹមនឹងនេះ គម្រោងវិនិយោគថ្មីៗ លើផ្នែកអគ្គិសនី (វារីអគ្គិសនី និងអគ្គិសនីដើរដោយធ្យូងថ្ម) រ៉ែ និងឧស្សាហកម្មធុនស្រាលដែលបាន និងកំពុងចាប់ផ្តើមនឹងរួមចំណែកក្នុងការជំរុញកំណើនលើវិស័យនេះថែមទៀត។ វិស័យសេវាកម្មអាចនឹងមានកំណើនប្រមាណ៦,៧% ដែលក្នុងនោះផ្នែកទេសចរណ៍អាចនឹងមានកំណើន៥,៩% ដោយសារតែចំនួនភ្ញៀវទេសចរ នឹងបន្តកើនឡើង ពិសេសភ្ញៀវពីក្នុងតំបន់។ ទន្ទឹមនឹងនេះ វិស័យហិរញ្ញវត្ថុអាចនឹងមានសន្ទុះកើនឡើងក្នុងពេលដែលទីផ្សារមូលបត្រត្រូវបានបង្កើត និងការជំរុញហិរញ្ញប្បទានក្នុងក្របខ័ណ្ឌគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។ លើសពីនេះ វិស័យអចលនវត្ថុ និងសំណង់ក៏រំពឹងថានឹងអាចងើបឡើងវិញផងដែរ ហើយដែលអាចជាសក្តានុពលជំរុញកំណើនក្នុងវិស័យនេះបន្ថែមទៀត។

៣- ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្របដែលបានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញយ៉ាងឆាប់រហ័សពី០,១% ក្នុងឆ្នាំ២០០៩ មក៦% ក្នុងឆ្នាំ២០១០ និង៧,១% ក្នុងឆ្នាំ២០១១ ហើយត្រូវបានព្យាករណ៍ថានឹងមានកំណើនប្រមាណ៧% ក្នុងឆ្នាំ២០១២ នេះ ពិតជាបានរួមចំណែកធ្វើឱ្យការអនុវត្តថវិកាសម្រេចបានលទ្ធផលល្អប្រសើរប្រាកដមែន។ ជាក់ស្តែងចំណូលសារពើពន្ធថវិការដ្ឋសរុបឆ្នាំ ២០១០ សម្រេចបាន១១៥,៣% ធៀបនឹងការអនុវត្តឆ្នាំ២០០៩ ស្មើនឹង១០,៦៧% នៃផសស និងឆ្នាំ២០១១ សម្រេចបាន១១២,៩% ធៀបនឹងការអនុវត្តឆ្នាំ២០១០ ស្មើនឹង១០,៨៩% នៃផសស។ តាមការព្យាករចំណូលសារពើពន្ធថវិការដ្ឋសរុបឆ្នាំ២០១២នេះ នឹងសម្រេចបាន១១៦,៨% ធៀបនឹងការអនុវត្តឆ្នាំ២០១១ ស្មើនឹង១១,៥៣% នៃផសស។ ដូច្នេះ បើគិតពីឆ្នាំ២០១០-២០១២ ចំណូលសារពើពន្ធបានកើនឡើងក្នុងមធ្យមភាគប្រមាណ១៥% ក្នុងមួយឆ្នាំ ធៀបនឹងការអនុវត្តចំណូលប្រចាំឆ្នាំ និងបានកើនឡើងក្នុងមធ្យមភាគប្រមាណ០,៤២% នៃផសស ក្នុងមួយឆ្នាំ។

៤- ទន្ទឹមនឹងការអនុវត្តនយោបាយវិត្ថារកម្ម ដើម្បីរួមចំណែកក្នុងការជំរុញឱ្យកំណើនសេដ្ឋកិច្ចឱ្យងើបឡើងវិញយ៉ាងឆាប់រហ័ស បញ្ហាព្រំដែន អតិផរណាខ្ពស់ និងទឹកជំនន់បានបង្កើនចំណាយថវិការដ្ឋសរុបរហូតដល់ជាង៥% នៃផសស ក្នុងអំឡុងឆ្នាំ២០០៩-២០១១ (ពី ១៦,២៣% នៃផសស នៅឆ្នាំ២០០៨ មក២០,៦២% នៅឆ្នាំ២០០៩ និងឡើងដល់ជាង២១% នៃផសសក្នុងឆ្នាំ២០១០ និង២០១១) ដែលបានធ្វើឱ្យឱនភាពថវិកាសរុបកើនឡើងរហូតដល់ជាង-៨% នៃផសស។ ប៉ុន្តែ ឱនភាពថវិកាសរុបនេះមិនស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរនោះទេ ព្រោះធាតុពិតឱនភាពជាង-៨% នៃផសស នេះសុទ្ធតែសម្រាប់ការវិនិយោគទាំងអស់ និងតាមរយៈហិរញ្ញប្បទានក្រៅប្រទេសដោយហិរញ្ញប្បទានឥតសំណង និងការខ្ចីដោយមានលក្ខណៈសម្បទាន។ ទោះជាយ៉ាងណារាជរដ្ឋាភិបាលមានគោលដៅកាត់បន្ថយចំណាយ និងបង្កើនប្រសិទ្ធភាពចំណាយ ព្រមទាំងពង្រឹង និងបង្កើនប្រសិទ្ធភាពប្រមូលចំណូល ដើម្បីកាត់បន្ថយឱនភាពថវិកាសរុបនេះ ឱ្យមកនៅត្រឹមកម្រិតប្រមាណ-៥% នៃផសស។ ដូច្នេះ ចំណាយថវិការដ្ឋសរុបឆ្នាំ២០១២ នឹងត្រូវបានរក្សាឱ្យនៅត្រឹមកម្រិត១៩,៣៣% នៃផសស ដែលក្នុងនោះ ចំណាយចរន្តនឹងត្រូវរក្សាឱ្យនៅត្រឹម១១,៤៥% នៃផសស និងចំណាយមូលធននឹងត្រូវរក្សាឱ្យ

នៅត្រឹម៧,៨៧% នៃផសស ដើម្បីរក្សាអតិរេកចរន្តប្រមាណ១,៨៥% និងឱនភាពថវិកាសរុបឱ្យនៅត្រឹម-៥,៨៨% នៃផសស។ ហើយនៅក្នុងឆ្នាំ២០១៣ ខាងមុខនេះ រាជរដ្ឋាភិបាលមានគោលដៅនឹងរក្សាចំណាយថវិការដ្ឋសរុបឱ្យនៅត្រឹមប្រមាណ១៩,២៧% នៃផសស (ថយចុះ០,១២% នៃផសស ធៀបនឹងឆ្នាំ២០១២) ដែលក្នុងនោះចំណាយចរន្ត នឹងត្រូវរក្សាឱ្យនៅត្រឹម១១,៣៦% នៃផសស (ថយចុះ០,០៩% នៃផសស ធៀបនឹងឆ្នាំ២០១២) និងចំណាយមូលធននឹងត្រូវរក្សាឱ្យនៅត្រឹម៧,៨៥% នៃផសស (ថយចុះ០,០២% នៃផសស ធៀបនឹងឆ្នាំ២០១២) ដើម្បីរក្សាអតិរេកចរន្តប្រមាណ២,៣៣% និងឱនភាពថវិកាសរុបឱ្យនៅត្រឹម-៥,២៧% នៃផសស។ ទោះជាយ៉ាងណា ដើម្បីសម្រេចបានតាមគោលដៅនេះ បញ្ហាប្រឈមគឺការជំរុញការប្រមូលចំណូលឱ្យបានតាមគោលដៅនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

៥- តាមការព្យាករការអនុវត្តថវិកាឆ្នាំ២០១២ គឺចំណូលថវិការដ្ឋសរុបអាចនឹងសម្រេចបាន ១០០,១% នៃច្បាប់ ហើយបើធៀបទៅនឹងការអនុវត្តឆ្នាំ២០១១ នឹងកើនឡើង ៧,៩% ដែលក្នុងនោះ ចំណូលក្នុងស្រុកនឹងសម្រេចបាន១០០,១% នៃច្បាប់ នឹងកើនឡើង១៥,៨% (ចំណូលសារពើពន្ធនឹងកើន១៦,៨% និងចំណូលមិនមែនសារពើពន្ធនឹងកើនឡើង១០%) ធៀបទៅនឹងការអនុវត្តឆ្នាំ២០១១។ ចំណូលក្នុងស្រុកសរុបអាចនឹងសម្រេចបានប្រមាណ១៣,៤៤% នៃផសស ដែលក្នុងនោះចំណូលសារពើពន្ធនឹងសម្រេចបាន១១,៥៣% នៃផសស (ក្នុងនោះចំណូលគយ និងរដ្ឋាករស្មើនឹង៦,០២% និងចំណូលពន្ធដារស្មើនឹង៥,១២%) ចំណូលមិនមែនសារពើពន្ធនឹងសម្រេចបាន១,៧៧% នៃផសស។ ទោះជាមានតម្រូវការចំណាយចាំបាច់ជាច្រើនពិសេស ការចំណាយសម្រាប់ការបោះឆ្នោត ការវិនិយោគលើបណ្តាញអគ្គិសនី កិច្ចប្រជុំអាស៊ាន និងគ្រោះទឹកជំនន់ តែចំណាយសរុបអាចនឹងថយចុះមកនៅត្រឹម១៩,៣៣% នៃផសស គឺនឹងថយចុះប្រមាណ១,៩៧% នៃផសស និងប្រហាក់ប្រហែលនឹងការអនុវត្តឆ្នាំ២០១១ ដែលក្នុងនោះចំណាយចរន្តនឹងសម្រេចបាន ១១,៤៥% នៃផសស គឺកើនឡើង៨,៣% ធៀបនឹងការអនុវត្តឆ្នាំ២០១១ និងចំណាយមូលធនសរុបអាចនឹងធ្លាក់ចុះមកនៅត្រឹម៧,៨៧% នៃផសស គឺថយចុះប្រមាណ៩,៨% ធៀបនឹងការអនុវត្តឆ្នាំ២០១១ ដែលក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស ២,៤៦% នៃផសស គឺថយចុះ២,៥% ធៀបនឹងការអនុវត្តឆ្នាំ២០១១ រីឯហិរញ្ញប្បទានក្រៅប្រទេសអាចនឹងធ្លាក់មកនៅត្រឹម៤,៩៨% នៃផសស គឺថយចុះ១៥,៩% ធៀបនឹងការអនុវត្តឆ្នាំ២០១១។ ការអនុវត្តចំណូល និងចំណាយនេះ អាចនឹងធ្វើឱ្យមានអតិរេកចរន្តប្រមាណ១,៨៥% នៃផសស និងឱនភាពថវិកាសរុបប្រមាណ-៥,៨៨% នៃផសស។

## II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៣

### ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៦- ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅឆ្នាំ២០១១ មានលក្ខណៈល្អប្រសើរ ហើយបានងើបឡើងវិញយ៉ាងខ្លាំងក្លា។ តាមការគណនារបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានបង្ហាញថាកំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១១ សម្រេចបានប្រមាណ៧,១% ក្នុងនោះវិស័យកសិកម្មបានបន្តមានកំណើនប្រមាណ៣,១% ទោះជាត្រូវបានជួបប្រទះគ្រោះទឹកជំនន់ក្តី វិស័យឧស្សាហកម្មមានកំណើន១៤,៥% និងវិស័យសេវាកម្មមានកំណើន៥%។ តាមការព្យាករដោយប្រយ័ត្នប្រយែង និងដោយផ្អែកលើនិន្នាការសេដ្ឋកិច្ចដើមឆ្នាំនេះ កំណើន សេដ្ឋកិច្ច

ឆ្នាំ២០១២ នេះអាចនឹងបន្តសម្រេចបានក្នុងរង្វង់៧% គឺលើសពីការគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ដែលបានព្យាករណ៍ត្រឹមតែ៦,៥%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៣,៥% ដោយសារការបន្តកើនឡើងនៃដំណាំស្រូវ កៅស៊ូ និងបណ្តាដំណាំដែលកំពុងមានសក្តានុពលនៅលើទីផ្សារដទៃទៀតដូចជា ពោត សណ្តែក និងដំឡូងមីជាដើម។ វិស័យឧស្សាហកម្ម នឹងមានកំណើន ១០,២% ដោយសារការបន្តកើនឡើងនៃផ្នែកវាយនភ័ណ្ឌ ការកែច្នៃ សំណង់ និងអគ្គិសនី។ វិស័យសេវាកម្មនឹងមានកំណើន៦,៩% ដែលកំណើននេះបានមកពីការបន្តមានកំណើននៃវិស័យទេសចរណ៍ ហិរញ្ញវត្ថុ និងធនាគារ អចលនវត្ថុ និងពាណិជ្ជកម្ម ព្រមទាំងការដឹកជញ្ជូន និងទូរគមនាគមន៍។

៧- ទោះជាយ៉ាងណា ស្ថានភាពឆ្នាំ២០១២ នេះនៅមានហានិភ័យខ្ពស់និងបញ្ហាប្រឈមនៅឡើយ ពិសេសដោយសារស្ថានភាពវិបត្តិនៅអឺរ៉ុបនៅតែបន្ត និងការងើបឡើងវិញដ៏យឺតនៃសេដ្ឋកិច្ចអាមេរិក ដែលបាន និងកំពុងបន្តធ្វើឱ្យថមថយតម្រូវការទីផ្សារសម្រាប់អាស៊ី ហើយដែលកំពុងមានសញ្ញាណធ្លាក់ចុះនៃការនាំចេញពីអាស៊ី។ ទន្ទឹមនឹងនេះ ស្ថិរភាពសេដ្ឋកិច្ចកម្ពុជាកាន់តែផ្សារភ្ជាប់ទៅនឹងស្ថិរភាពហិរញ្ញវត្ថុ ក្នុងពេលដែលទីផ្សារហិរញ្ញវត្ថុកាន់តែរីកចម្រើន និងចាក់ឫសកាន់តែជ្រៅទៅក្នុងប្រព័ន្ធសេដ្ឋកិច្ច។ ជាក់ស្តែងការបន្តកើនឡើងនៃឥណទានក្នុងអត្រាខ្ពស់ (៣៥%) គឺជាសញ្ញាហានិភ័យដល់ស្ថិរភាពហិរញ្ញវត្ថុ ទោះជាអត្រានៃការខ្ចីគ្មានសមិទ្ធកម្មនៅមានកម្រិតទាបក៏ដោយ។ ដូច្នេះរាជរដ្ឋាភិបាល ពិសេសធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបន្តអប្បមាទជាប្រចាំ និងប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ពិសេសត្រូវបង្កើនការគ្រប់គ្រងលើការផ្តល់ឥណទាន ដើម្បីធានាការផ្តល់អាទិភាពដល់វិស័យដែលមានផលិតភាពខ្ពស់ ហើយក្នុងករណីចាំបាច់ អាចនឹងតម្រូវឱ្យបង្កើនទុនបម្រុងរបស់ធនាគារ ដើម្បីកាត់បន្ថយហានិភ័យនៃស្ថិរភាពហិរញ្ញវត្ថុ។

៨- កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៣ តាមការព្យាករអាចនឹងបន្តសម្រេចបានក្នុងរង្វង់៧%។ កំណើននេះនឹងបានមកដោយសារវិស័យកសិកម្មអាចនឹងបន្តរក្សាកំណើនបានក្នុងរង្វង់៣,៨% ពិសេសគឺដោយសារការបន្តកើនឡើងនៃដំណាំស្រូវដែលជាសមិទ្ធផលនៃការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងលទ្ធភាពនៃការនាំចេញកសិផលដទៃទៀតដែលកំពុងមានសក្តានុពលលើទីផ្សារ ដូចជា កៅស៊ូ ពោត សណ្តែក និងដំឡូងមី ព្រមទាំងបណ្តាកសិផលបន្ទាប់បន្សំផ្សេងៗទៀត។ វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ១០,៣% ដោយរំពឹងថាវិស័យវាយនភ័ណ្ឌនឹងអាចកើនឡើងប្រមាណ១១,៧% យោងលើការចាប់ផ្តើមងើបឡើងវិញនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងសញ្ញាវិជ្ជមាននៃសេដ្ឋកិច្ចអឺរ៉ុប ដែលសុទ្ធសឹងជាទីផ្សារធំៗសម្រាប់កម្ពុជា។ ទន្ទឹមនឹងនេះ កម្ពុជាក៏កាន់តែមានលទ្ធភាពធ្វើពិពិធកម្មទីផ្សារវាយនភ័ណ្ឌទៅក្នុងតំបន់ផង និងឧត្តមភាពប្រៀបធៀបរបស់កម្ពុជាកាន់តែកើនឡើងផង ដែលអាចធ្វើឱ្យមានការផ្ទេររោងចក្រពីបណ្តាប្រទេសក្នុងតំបន់មកកម្ពុជា។ លើសពីនេះ គម្រោងវិនិយោគមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី ទាំងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម នឹងចាប់ផ្តើមដំណើរការអាជីវកម្មកាន់តែច្រើនឡើង ស្របពេលនឹងគម្រោងផ្សេងៗទៀតក្នុងវិស័យរ៉ែ និងកម្មន្តសាល ពិសេសសកម្មភាពឧស្សាហកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេសក៏នឹងចាប់ផ្តើមពង្រីកសកម្មភាពកាន់តែខ្លាំងក្លាជាងមុន។ វិស័យសេវាកម្មអាចនឹងសម្រេចបានកំណើនប្រមាណ ៦,៧% ដោយសារតែចំនួនភ្ញៀវទេសចរនឹងបន្តកើនឡើង ពិសេសពីក្នុងតំបន់អាស៊ីដែលបាន និងកំពុងក្លាយជាតំបន់នាំមុខនៃសេដ្ឋកិច្ចសាកលលោក។ ទន្ទឹមនឹងនេះ វិស័យហិរញ្ញវត្ថុអាចនឹងមានសន្ទុះកាន់តែខ្លាំងឡើង ដើម្បី

ឆ្លើយតបទៅនឹង និងទ្រទ្រង់ដល់សកម្មភាពសេដ្ឋកិច្ចជាទូទៅ ស្របពេលនឹងការបង្កើតទីផ្សារមូលបត្រដែលនឹងជួយជំរុញសកម្មភាពហិរញ្ញវត្ថុឱ្យកាន់តែសកម្មថែមទៀត។ វិស័យអចលនវត្ថុ និងសំណង់ក៏រំពឹងថានឹងបន្តងើបឡើងវិញជាបណ្តើរៗ ដោយសារកំណើនចំណូលរបស់ប្រជាជន គោលនយោបាយជំរុញឱ្យមានការសាងសង់អគារខ្ពស់ៗ និងការអនុញ្ញាតឱ្យជនបរទេសមានកម្មសិទ្ធិលើអគារសហកម្មសិទ្ធិ។

៩- ក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ អតិផរណានៅកម្ពុជាបានរងឥទ្ធិពលពីកំណើនថ្លៃម្ហូបអាហារ ថ្លៃប្រេងឥន្ធនៈ និងថ្លៃវត្ថុធាតុដើមលើទីផ្សារអន្តរជាតិពិសេសតាមរយៈការនាំចូល ដែលឥទ្ធិពលនេះបានធ្វើឱ្យអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០០៨ ឡើងរហូតដល់១៩,៧%។ ប៉ុន្តែ ដោយសារការឆ្លើយតបទាន់ពេលវេលារបស់រាជរដ្ឋាភិបាលតាមរយៈការដាក់ចេញនូវវិធានការ និងគោលនយោបាយជាកញ្ចប់ប្រកបដោយប្រសិទ្ធភាព ជាពិសេសការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុដ៏សមស្រប និងប្រយ័ត្នប្រយែង អត្រាអតិផរណាបានធ្លាក់ចុះមកនៅក្នុងកម្រិតមួយសមស្រប និងអាចគ្រប់គ្រងបាន។ ជាក់ស្តែង អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០១១ បានធ្លាក់មកនៅត្រឹម៥,៥% ហើយតាមការព្យាករនៅឆ្នាំ ២០១២ នេះនឹងមានកម្រិតត្រឹមប្រមាណ៥% ដូចបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២។ លើសពីនេះ ការសម្រេចចិត្តខាងនយោបាយរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផល នៅក្នុងក្របខ័ណ្ឌទូទាំងប្រទេសនាពេលថ្មីៗនេះ មិនត្រឹមតែបានបង្កើនប្រសិទ្ធភាព និងសមធម៌ក្នុងអាជីវកម្មនេសាទ និងការអភិរក្សពូជត្រីប៉ុណ្ណោះទេ តែព្រមទាំងបាន និងកំពុងរួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយសម្ពាធអតិផរណានៅកម្ពុជា និងធ្វើឱ្យអតិផរណាមានការធ្លាក់ចុះថែមទៀតផង។ តាមការព្យាករអត្រាអតិផរណានៅឆ្នាំ២០១៣ ខាងមុខនឹងមានកម្រិតត្រឹមប្រមាណ៤% ដោយសារការលុបឡូតិ៍នេសាទទូទាំងប្រទេសនេះផង និងដោយសារនិន្នាការនៃការធ្លាក់ចុះនៃអត្រាអតិផរណារបស់បណ្តាប្រទេសជិតខាងផង។

១០- អត្រាប្តូរប្រាក់ត្រូវបានរក្សាឱ្យមានស្ថិរភាពល្អប្រសើរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅឆ្នាំ២០១០ ប្រាក់រៀលមានតម្លៃជាមធ្យម៤ ១៧៤រៀល/ដុល្លារអាមេរិក ហើយនៅឆ្នាំ២០១១ មានតម្លៃជាមធ្យម ៤ ០៧៦រៀល/ដុល្លារអាមេរិក។ នៅដើមឆ្នាំ២០១២ នេះ ប្រាក់រៀលបានឡើងថ្លៃដល់ប្រមាណ៤ ០៥០រៀល/ដុល្លារអាមេរិក ហើយតម្លៃប្រាក់រៀលនឹងបន្តស្ថិតក្នុងកម្រិតជាមធ្យមប្រមាណ៤ ០៥០រៀល/ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១២ នេះនិងឆ្នាំ២០១៣ ខាងមុខ។ អត្រាប្តូរប្រាក់នេះមានកម្រិតទាបជាងអត្រាប្តូរប្រាក់ ដែលបានកំណត់ចំនួន៤ ១០០រៀល/ដុល្លារអាមេរិកនៅក្នុង **«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣»** ដោយសារការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក និងការធ្លាក់ចុះតម្លៃប្រាក់ដុល្លារអាមេរិក។ ការរក្សាស្ថិរភាពនៃអត្រាប្តូរប្រាក់នេះ គឺជាយុទ្ធសាស្ត្របង្កើនទំនុកចិត្តមកលើប្រាក់រៀល បង្កើនតម្រូវការ និងចរាចរប្រាក់រៀល ដើម្បីកាត់បន្ថយដុល្លាររូបនីយកម្ម ហើយក៏ជួយរក្សាតុល្យភាពផលប្រយោជន៍រវាងអ្នកមានចំណូលជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកផងដែរ។

១១- ឱនភាពគណនីចរន្តមាននិន្នាការថយចុះជាលំដាប់គឺពី-១០,១% នៃផសស នៅឆ្នាំ២០១០ មក -៧,៣% នៃផសស នៅឆ្នាំ២០១១។ តាមការព្យាករឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះមកនៅត្រឹមតែ-៦% នៅឆ្នាំ ២០១២ និង-៥,៩% នៅឆ្នាំ២០១៣។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញរបស់

កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឱ្យការនាំចូលជាបណ្តើរៗ។ ម្យ៉ាងទៀត សេដ្ឋកិច្ចកម្ពុជាបាននិងកំពុងធ្វើសមាហរណកម្មយ៉ាងជិតស្និទ្ធទៅនឹងទីផ្សារ ដែលបាននិងកំពុងផ្តល់ឱកាសដល់ការពង្រីកទំហំពាណិជ្ជកម្មដោយគ្មានដែនកំណត់។ ទុនបម្រុងអន្តរជាតិបានកើនឡើងពី២,៦៥ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០១០ ដល់២,៩៧ ពាន់លានដុល្លារអាមេរិកនៅឆ្នាំ២០១១។ ទុនបម្រុងអន្តរជាតិនឹងបន្តរក្សាបាននូវចលនាការកំណើនដដែល ហើយអាចធានាបាននូវការនាំចូលប្រមាណជាង៤ខែ នៅក្នុងឆ្នាំ២០១២ និង២០១៣ខាងមុខនេះ។

១២- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ មានគោលបំណងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនប្រកបដោយចីរភាព និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងគ្រប់គ្រងស្ថិរភាពថ្លៃនៅលើទីផ្សារ និងចីរភាពបំណុលជាទូទៅ ដើម្បីសម្រេចបាននូវគោលដៅរយៈពេលមធ្យមនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលដូចមានចែងក្នុង **«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣»** ពោលគឺបន្តខិតខំដើម្បី (១)សម្រេចបាននូវអត្រាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៦-៧% (២)រក្សាអត្រាអតិផរណាឱ្យស្ថិតនៅក្រោម៥% (៣)កំណត់បំណុលបរទេសឱ្យមានកម្រិតប្រហាក់ប្រហែលនឹងលំហូរនៃហិរញ្ញប្បទាន និងការវិនិយោគផ្ទាល់ពីបរទេស និង(៤)រក្សាទុនបម្រុងអន្តរជាតិឱ្យស្មើនឹងការនាំចូលចំនួនបីខែ។ ***ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅនៃកំណើនផលសរុបក្នុងស្រុកឱ្យសម្រេចបានក្នុងរង្វង់៧% នៅឆ្នាំ២០១២ និងឆ្នាំ២០១៣ និងខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្នុងរង្វង់៥% ក្នុងឆ្នាំ២០១២ និង៤% ក្នុងឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងធានារក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀល ឱ្យស្ថិតនៅក្នុងរង្វង់ជុំវិញ៤ ០៥០រៀល/ដុល្លារអាមេរិក ក្នុងគោលដៅជំរុញឱ្យមានវិដុល្លារូបនីយកម្មក្នុងរយៈពេលវែងចំពោះមុខតាមរយៈការបង្កើនការប្រើប្រាស់ប្រាក់រៀល។*** ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់នឹងកើនឡើងដល់ប្រមាណ៩៨១ ដុល្លារអាមេរិក នៅឆ្នាំ២០១២នេះ និងប្រមាណ១ ០៦៤ដុល្លារអាមេរិក នៅឆ្នាំ២០១៣ ខាងមុខ។ លើសពីនេះ សម្រាប់រយៈពេលមធ្យមខាងមុខ (២០១៣-២០១៥) រាជរដ្ឋាភិបាលមានគោលដៅរក្សាកំណើនប្រចាំឆ្នាំឱ្យបានក្នុងរង្វង់៧% អត្រាអតិផរណាក្នុងរង្វង់៤% និងអត្រាប្តូរប្រាក់រៀលក្នុងរង្វង់៤ ១០០រៀល/ដុល្លារអាមេរិក។

## ***ខ- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកា***

១៣- ដោយផ្អែកលើមូលដ្ឋាននៃ **«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២»** និង**«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣»** គោលនយោបាយហិរញ្ញវត្ថុសាធារណៈមានគោលដៅសំខាន់ៗដូចតទៅ ÷

- ធានាការបន្តអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ជាពិសេស ការបន្តជំរុញការអនុវត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ***ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព*** នៅកម្ពុជារបស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ ២០១៣-២០១៥។

• ធានាការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** ដូចជា÷

- ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកម្ពស់សេវាសាធារណៈនៅក្នុងវិស័យសង្គមកិច្ច ជាពិសេសវិស័យអប់រំ សុខាភិបាល និងសុវត្ថិភាពសង្គម។
- ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកម្ពស់សកម្មភាពដែលបម្រើឱ្យវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍជនបទ។

• ធានាបន្តអនុវត្តកម្មវិធីកែទម្រង់ កម្មវិធីអភិវឌ្ឍន៍គ្រប់ការដ្ឋាន និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

• ធានាបន្តការពារឱ្យបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី និងធានាបម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ។

• ធានាផ្តល់ការឆ្លើយតបដោយទាន់ពេលវេលា និងដោយប្រសិទ្ធភាពចំពោះវិបត្តិ និងឧបទ្ទវហេតុផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ដូចជាគ្រោះធម្មជាតិជាដើម។

១៤- ដើម្បីឈានទៅសម្រេចគោលដៅខាងលើនេះ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់លើការធានាឱ្យបាននូវតុល្យភាពទាំងឥណទាន និងទាំងសាច់ប្រាក់។ ធ្វើដូចនេះ ដើម្បីរក្សាអតិរេកជាសាច់ប្រាក់សម្រាប់បំពេញតម្រូវការចំណាយឆ្នាំបន្ទាប់ និងសម្រាប់ត្រៀមបម្រុងទប់ទល់នឹងវិបត្តិដែលអាចកើតមានជាយថាហេតុពិសេសដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពជឿទុកចិត្តនៃថវិកា ព្រមទាំងត្រៀមសម្រាប់បម្រើឱ្យការអនុវត្តគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវដាក់ចេញនាពេលខាងមុខ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងធានាឱ្យបាននូវសមតុល្យសាច់ប្រាក់ក្នុងចន្លោះពី១៥០ ទៅ២៥០ពាន់លានរៀល តាមរយៈការកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈដូចខាងក្រោម÷

• អតិរេកថវិកាចរន្តត្រូវធានាឱ្យបានក្នុងរង្វង់១,៨៥% នៃផសស សម្រាប់ឆ្នាំ២០១២ និង២,៣៣% នៃផសសសម្រាប់ឆ្នាំ២០១៣។ និនភាពថវិកាសរុបនឹងត្រូវកាត់បន្ថយពី-៨,៤៩% នៃផសស នៅឆ្នាំ២០១១ មកនៅត្រឹម-៥,៨៨% នៃផសស នៅឆ្នាំ២០១២ និង-៥,២៧% នៃផសស នៅឆ្នាំ២០១៣។

• ចំណូលក្នុងស្រុកសរុបនៅឆ្នាំ២០១២ ត្រូវសម្រេចឱ្យបាន១៣,៤៤%នៃផសស (ថ្នាក់ជាតិ ១២,៨៦% និងថ្នាក់ក្រោមជាតិ០,៥៨%)។ ក្នុងនោះ ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវសម្រេចឱ្យបាន៦,០២% នៃផសស និងចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឱ្យបាន៥,១២% នៃផសស (ថ្នាក់ជាតិ៤,៥៨% និងថ្នាក់ក្រោមជាតិ០,៥៤%) ហើយចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន១,៧៧% នៃផសស (ថ្នាក់ជាតិ១,៧៣% និងថ្នាក់ក្រោមជាតិ០,០៤%)។ ទន្ទឹមនឹងនេះ ចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឱ្យបាន០,១៤% នៃផសស។

• ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ២០១៣ ត្រូវសម្រេចឱ្យបានស្មើនឹង១៣,៩៤% នៃផសស (ថ្នាក់ជាតិ១៣,៣៤% និងថ្នាក់ក្រោមជាតិ០,៦០%)។ ក្នុងនោះចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវសម្រេចឱ្យបាន៦,៣២% នៃផសស និងចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឱ្យបាន៥,២៩%

នៃផសស (ថ្នាក់ជាតិ៤,៧៣% និងថ្នាក់ក្រោមជាតិ០,៥៦%) ហើយចំណូលមិនមែនសារពើពន្ធសរុបត្រូវសម្រេចឱ្យបាន១,៦៨% នៃផសស (ថ្នាក់ជាតិ១,៦៤% និងថ្នាក់ក្រោមជាតិ០,០៤%)។ ទន្ទឹមនឹងនេះ ចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឱ្យបាន០,២៤% នៃផសស។

- ចំណាយថវិការដ្ឋសរុបត្រូវរក្សាឱ្យនៅត្រឹម១៩,៣៣%នៃផសស (ថ្នាក់ជាតិ១៨,៧៥% និងថ្នាក់ក្រោមជាតិ០,៧៤%) នៅឆ្នាំ២០១២ ដោយចំណាយចរន្តថវិការដ្ឋត្រូវរក្សាឱ្យបានត្រឹម១១,៤៥% នៃផសស (ថ្នាក់ជាតិ១១,០២% និងថ្នាក់ក្រោមជាតិ០,៦%)។ ចំណាយថវិការដ្ឋសរុបសម្រាប់ឆ្នាំ២០១៣ ត្រូវរក្សាឱ្យនៅត្រឹម១៩,២៧% នៃផសស (ថ្នាក់ជាតិ១៨,៦១% និងថ្នាក់ក្រោមជាតិ០,៧១%) ដោយចំណាយចរន្តថវិការដ្ឋនឹងកម្រិតត្រឹម១១,៣៦% នៃផសស (ថ្នាក់ជាតិ១០,៨៩% និងថ្នាក់ក្រោមជាតិ០,៥៧%)។ ទន្ទឹមនឹងនេះ ចំណាយមូលធនថវិការដ្ឋសរុបត្រូវរក្សាត្រឹមកម្រិត៧,៨៧% នៃផសស នៅឆ្នាំ២០១២ និង៧,៨៥% សម្រាប់ឆ្នាំ២០១៣។

- ជារួមសម្រាប់រយៈពេលមធ្យម (២០១៣-២០១៥) រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ ដើម្បីបន្តពង្រឹងការប្រមូលនិងការគ្រប់គ្រងចំណូលឱ្យបានតាមគោលដៅកំណើនចំណូលប្រចាំឆ្នាំប្រមាណ០,៥% នៃផសស និងបន្តពង្រឹងការរៀបចំ និងការអនុវត្តចំណាយឱ្យកាន់តែមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពក្នុងគោលដៅរក្សានិនភាពថវិកាសរុបឱ្យស្ថិតក្នុងកម្រិតស្ថិរភាពគឺក្រោម-៥% នៃផសស។

**១៥-** ទន្ទឹមនឹងនេះ ដើម្បីធានាបាននូវការអនុវត្តតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ២០១៣ ត្រូវគ្រោង និងរៀបចំឡើងលើគោលការណ៍**«បង្កើនការប្រមូលចំណូលបន្ថែមហើយពង្រឹងវិន័យ និងបង្កើនគុណភាពចំណាយ»** ដោយផ្អែកលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម ÷

- បន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- បន្តពង្រឹងការរៀបចំថវិកាឱ្យកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និងសុក្រឹតភាព តាមរយៈការបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឱ្យបានច្បាស់លាស់ និងសុក្រឹត ការធ្វើសមាហរណកម្មថវិកា និងការបន្តកែលម្អការអនុវត្តថវិកាតាមកម្មវិធី។

- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស បន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងពាក់កណ្តាលឆ្នាំ ការបន្តពង្រឹងការអនុវត្តវិសហមជ្ឈការលទ្ធកម្មសាធារណៈ រឹតបន្តឹងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្រៅដើម្បីបន្តពង្រឹង ***ភាពជឿទុកចិត្តបាននៃថវិកា***

ដែលសម្រេចបាននៅក្នុងជំហានទី១ ដែលនឹងនៅតែជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់សម្រាប់អនុវត្តកម្មវិធីជំហានទី២ ***គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** និងបណ្តាជំហានបន្តបន្ទាប់ទៀត។

- បន្តពង្រឹង និងបង្កើនការអនុវត្តប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្មី ប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុឱ្យកាន់តែសុក្រឹត ព្រមទាំងការត្រួតពិនិត្យផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្រៅ ជាពិសេសចាប់ផ្តើមកំណត់ និងដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់មុខងារ អង្គភាពថវិកា ឬរបថនិងនីតិវិធីអនុវត្តថវិកាថ្មី ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាដែលជាសកម្មភាពការងារដ៏ចំបងសម្រាប់សម្រេចជំហានទី២ គឺ***ការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រតាមប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម ការធ្វើអធិការកិច្ច និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា។
- ពង្រឹងការគ្រប់គ្រងសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ពិសេសការបង់ពន្ធ និងការបង់ចំណែកនៃប្រាក់ចំណេញជូនរដ្ឋ។
- បន្តការរឹតត្បិតចំណាយចរន្ត ដោយត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ធ្វើវិចារណកម្មចំណាយ និងការធ្វើអាទិភាវូបនីយកម្មចំណាយ ជាពិសេស ត្រូវបន្តពង្រឹងការគោរពវិន័យជប់មួយយ៉ាងតឹង ការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ ត្រូវបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ជៀសវាងបេសកកម្មបរទេស ឬការចូលរួមប្រជុំនៅបរទេស ឬការរៀបចំប្រជុំនៅក្នុងប្រទេសដែលពុំសូវចាំបាច់ ការបញ្ឈប់ការទិញសម្ភារៈប្រណិត ការទិញសម្ភារៈថ្មី និងការបោះពុម្ពដែលពុំសូវចាំបាច់ ព្រមទាំងផ្អាកការសាងសង់អគារថ្មី ឬការជួសជុលដែលពុំចាំបាច់។
- អនុវត្តឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ពិសេសគឺត្រូវជំរុញការអនុវត្តទស្សនាទានស្តីពីតម្លៃនៃលុយ ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពចំណាយ។
- បន្តពង្រឹងការគ្រប់គ្រង និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកអណ្តែត និងមន្ត្រីជាប់កិច្ចសន្យា។

១៦- លើសពីនេះ ដើម្បីឱ្យក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើអាចសម្រេចបានតាមគោលដៅ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តបណ្តាគោលនយោបាយ និងកម្មវិធីកែទម្រង់សំខាន់ៗដូចខាងក្រោម ÷

*ក.* បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដ៏ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាពក្នុងបរិការណ៍នៃអត្រាអតិផរណាសមស្រប។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តអប្បមាទជាប្រចាំ និងត្រៀមដាក់ចេញនូវបណ្តាវិធានការគោលនយោបាយថវិកា ឬ/និងគោលនយោបាយរូបិយវត្ថុប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងទាន់ពេលវេលា ដើម្បីទប់ទល់នឹង និងគ្រប់គ្រងលើសម្ពាធអតិផរណា និងការប្រែប្រួលនៃលំហូរមូលធន ដែលបាន និងកំពុងរាលដាល និងមានការយកចិត្តទុកដាក់ខ្ពស់នៅក្នុងតំបន់ក៏ដូចជានៅលើសកលលោក។

*ខ.* បន្តជំរុញការអភិវឌ្ឍតាមវិស័យ ពិសេស វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ បន្តជំរុញ និងបង្កើន ការលើកស្ទួយវិស័យកសិកម្ម កសិឧស្សាហកម្ម និងជួយគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ពិសេស ជំរុញ ការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ព្រមទាំងជំរុញ និងលើកទឹកចិត្តដល់ ផលិតកម្មនៃបណ្តាកសិផលមួយចំនួនទៀតដែលកំពុងមានសក្តានុពលខ្ពស់ ដូចជា ដំឡូងមី ពោត និងកៅស៊ូ។ បន្តយកចិត្តទុកដាក់ខ្ពស់លើការបង្កើនគុណភាពសេវាវិស័យអប់រំ សុខាភិបាល និងការកសាងធនធានមនុស្ស ព្រមទាំងការងារបង្កើនសុវត្ថិភាពសង្គម។ បន្តជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ប្រព័ន្ធ ស្រោចស្រព ព្រមទាំងបន្តបង្កបរិយាកាស និងផ្តល់ការលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជន ពិសេស ការវិនិយោគក្នុងវិស័យកសិកម្ម និងតាមរយៈយន្តការជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

*គ.* បន្តជំរុញការអនុវត្តកំណែទម្រង់ការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបោសសម្អាត មីន ដោយផ្តោតជាសំខាន់លើការពង្រឹងប្រព័ន្ធគ្រប់គ្រង ការបែងចែកដីធ្លីប្រកបដោយសមធម៌ ការប្រើប្រាស់ ដីធ្លីប្រកបដោយប្រសិទ្ធភាព ក្នុងនោះរួមទាំងដីសម្បទានសេដ្ឋកិច្ច ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និង ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លីឱ្យសមស្របតាមច្បាប់ភូមិបាល ដើម្បីជួយគាំទ្រដល់វិស័យកសិកម្ម សំដៅ លើកកម្ពស់ផលិតភាព និងពិពិធកម្មរូបនីយកម្មកសិកម្ម ដើម្បីឱ្យវិស័យនេះក្លាយទៅជាមូលដ្ឋានដ៏រឹងមាំនៃ កំណើនសេដ្ឋកិច្ច ហើយជាបណ្តើរៗឈានទៅកសាងវិស័យឧស្សាហកម្ម ដោយផ្តើមចេញពីឧស្សាហកម្មកែច្នៃ កសិផល និងក្នុងគោលដៅធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងបម្រើឱ្យគោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់ប្រជាជន។

*ឃ.* បន្តពង្រឹង និងពង្រីកប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង ទីផ្សារមូលបត្រ និងទីផ្សារភាគហ៊ុន ក្នុងក្របខ័ណ្ឌនៃការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីបង្កើនការគៀរគរធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងបង្កើនសក្តានុពលភាព និងកាលានុវត្តភាពដល់ការធ្វើហិរញ្ញប្បទាន និងការ អភិវឌ្ឍវិស័យឯកជន។

*ង.* បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ ជាពិសេស បន្តជំរុញការអនុវត្តផែនការសកម្មភាពជំហានទី២ គឺ ***ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ*** ដោយផ្តោតលើ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់ថវិកាថ្មីបន្ថែមទៀត អង្គភាពថវិកា ស្តង់ដារគណនេយ្យ ប្រព័ន្ធ ត្រួតពិនិត្យផ្ទៃក្នុង និងការសាកល្បងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា។ ទន្ទឹមនឹងនេះ ***ការបន្ត ពង្រឹងភាពជឿទុកចិត្តលើថវិកា*** នៃជំហានទី១ តាមរយៈការបន្តជំរុញការកែលម្អនីតិវិធីចំណាយ ការបន្ត ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាឱ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា។ ការបន្តកសាង និងកែ លម្អក្របខ័ណ្ឌគោលនយោបាយចំណូលរយៈពេលមធ្យមដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពចំណូល ពិសេស ផ្តោតការយកចិត្តទុកដាក់លើការកសាង និងពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ យន្តការគ្រប់គ្រង និងការប្រមូល ពន្ធ និងអាករ ព្រមទាំងចំណូលមិនមែនសារពើពន្ធ រួមទាំងចំណូលពីធនធានធម្មជាតិផង។ លើសពីនេះ ត្រូវបន្តជំរុញពង្រឹង និងបង្កើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ដែលជាមូលដ្ឋានដ៏ សំខាន់ និងចាំបាច់ ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាបណ្តើរៗ និងដើម្បីឈានទៅ***បង្កើនការ***

*ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* និង*ការបង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម* ដែលជាគោលដៅនៃជំហានទី៣ និងទី៤។

*ច.* បន្តជំរុញ **ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ពិសេស ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល ច្បាប់ និងលិខិតគតិយុត្តិផ្សេងៗ ដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងន័យនេះ **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)** និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវសហការរៀបចំកម្មវិធីសកម្មភាពឱ្យបានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ជាជំហានៗ ប្រកបដោយភាពហ្មត់ចត់ និងប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាការអនុវត្តប្រកបដោយភាពរលូន និងប្រសិទ្ធភាព។ ពិសេស ការពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុរបស់គ្រប់ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការផ្ទេរអំណាច និងការទទួលខុសត្រូវពីថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព។

*ឆ.* បន្តជំរុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការកែលម្អការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ។ ក្នុងន័យនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវរៀបចំគោលនយោបាយរយៈពេលមធ្យម និងវែង សម្រាប់ការកែលម្អការគ្រប់គ្រងធនធានមនុស្សប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ជាពិសេសត្រូវបង្កើតយន្តការ និងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យក្របខ័ណ្ឌមន្ត្រីរាជការ ការពង្រឹងការផ្តល់ទិដ្ឋាការឱ្យរើសមន្ត្រីថ្មីបន្ថែមដោយផ្អែកលើការវិភាគលើតម្រូវការជាក់ស្តែង និងលទ្ធភាពថវិកាជាតិ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការចូលនិវត្តន៍។ ទន្ទឹមនឹងនេះ ត្រូវពិនិត្យពិចារណាឡើងវិញលើរាល់គោលនយោបាយ និងគោលការណ៍ដំឡើង និងផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ រួមទាំងការដំឡើងបៀវត្សមូលដ្ឋានប្រចាំឆ្នាំ ការដំឡើងកាំប្រាក់ ការអនុវត្តប្រាក់បំណាច់មុខងារ ការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចជា ប្រាក់ម៉ោង ប្រាក់យាម ប្រាក់បេសកកម្ម និងចំណាយប្រតិបត្តិការ អាទិភាពជាដើម ដើម្បីធានាសមធម៌ តម្លាភាព សង្គតិភាព និងប្រសិទ្ធភាព។

*ជ.* បន្តជំរុញការអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេស ការពង្រឹងសមត្ថភាពដឹកនាំ វិជ្ជាជីវៈជំនាញ សហប្រតិបត្តិការ និងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងការកែសម្រួលរចនាសម្ព័ន្ធកងឯកភាពប្រយុទ្ធ និងការកាត់បន្ថយកងទ័ព ដើម្បីធានាការប្រើប្រាស់ និងគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់។

*ឈ.* បន្តជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ពិសេស ការបន្តរៀបចំ និងពង្រឹងសមត្ថភាពអង្គភាពប្រឆាំងអំពើពុករលួយដើម្បីអាចដំណើរការ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក្នុងការអប់រំ ទប់ស្កាត់ និងបោសសម្អាតអំពើពុករលួយ។

## III. ការគណនា និងទិសដៅនៃថវិកាឆ្នាំ២០១៣

### ក- <u>គម្រោងចំណាយថវិកា</u>

១៧- ដើម្បីធានាបាននូវការអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈដែលបានកំណត់ខាងលើ ពិសេស ដើម្បីអនុវត្តតាមគោលការណ៍ និងវិធានការដូចបានគូសបញ្ជាក់ខាងលើ ការគ្រោងចំណាយថវិកាឆ្នាំ២០១៣ ត្រូវផ្អែកលើមូលដ្ឋាន *បង្កើនប្រសិទ្ធភាពចំណាយ* ដូចខាងក្រោម÷

• បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាសម្ភារៈ និងឧបករណ៍ទំនើបៗ ការជួសជុលធំៗ គ្រឿងសង្ហារិមប្រណិត ព្រមទាំងចំណាយអគ្គិសនី ទូរស័ព្ទ និងប្រេងឥន្ធនៈ ដើម្បីកាត់បន្ថយចំណាយថវិការដ្ឋសរុបឱ្យស្ថិតមកនៅត្រឹមកម្រិត១៩,២៧% នៃផសស គឺថយចុះ០,១៦% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ដែលក្នុងនោះចំណាយចរន្តថវិការដ្ឋសរុបនឹងត្រូវរក្សាឱ្យនៅត្រឹម១១,៣៦% នៃផសស (ថយចុះ០,០៩% នៃផសស ធៀបនឹងច្បាប់ឆ្នាំ២០១២) និងចំណាយមូលធននឹងត្រូវរក្សាឱ្យនៅត្រឹម៧,៨៥% នៃផសស (ថយចុះ០,០២% នៃផសស ធៀបនឹងច្បាប់ឆ្នាំ២០១២) ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់២,៣៣% នៃផសស និងឱនភាពថវិកាសរុបក្នុងរង្វង់-៥,២៧% នៃផសស។ ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងកម្រិត២,៤៣% នៃផសស គឺថយចុះ០,០៣% នៃផសសធៀបនឹងច្បាប់ឆ្នាំ២០១២ ក្នុងនោះចំណាយសម្រាប់រំលស់បំណុលត្រូវកំណត់ត្រឹម០,៤៤% នៃផសស គឺកើន១២% ធៀបនឹងច្បាប់ឆ្នាំ២០១២។ ទន្ទឹមនឹងនេះ ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវបានគ្រោងក្នុងកម្រិត៤,៩៧% នៃផសស គឺកើនប្រមាណ១០% ធៀបនឹងច្បាប់ឆ្នាំ២០១២។

• ត្រូវវិភាជន៍ចំណាយចរន្តទៅតាមវិស័យនីមួយៗ ដូចតទៅៈ វិស័យសង្គមកិច្ចស្មើនឹង៤,២៨% នៃផសស គឺស្មើនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ វិស័យសេដ្ឋកិច្ច០,៩០% នៃផសស ថយចុះ០,០៤% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ វិស័យរដ្ឋបាលទូទៅ១,៥៥% នៃផសស ថយចុះ០,០៧% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ វិស័យការពារជាតិ និងសន្តិសុខ២,៤២% នៃផសស ថយចុះ០,០១% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

• ថវិការាជធានី ខេត្ត ត្រូវកំណត់ត្រឹម០,៧១% នៃផសស ដែលក្នុងនោះថវិកាផ្ទាល់ របស់រាជធានី ខេត្តសរុបមានប្រមាណ០,៦០% នៃផសស មានកំណើន០,០២% នៃផសស ឬ១៤,៧% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិស្មើនឹង០,១១% នៃផសស។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំដោយឡែកសម្រាប់ការរៀបចំថវិកាថ្នាក់ក្រោមជាតិ ដោយឈរលើមូលដ្ឋាននៃសារាចរណែនាំនេះ ជាពិសេសការកំណត់កញ្ចប់ និងការវិភាជថវិកាទៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគោរពទៅតាមគោលការណ៍ និងវិធានតាមជំពូកដូចបានកំណត់នៅក្នុងសារាចរណែនាំនេះ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល និងប្រសិទ្ធភាពចំណាយ ដើម្បីកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

១៨- ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០១៣ ត្រូវបន្តបម្រើឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ព្រមទាំងការលើកស្ទួយជីវភាពប្រជាជននៅទីជនបទ សំដៅសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ថវិកាឆ្នាំ២០១៣ ត្រូវផ្តល់ការវិភាជជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗ ដូចខាងក្រោមៈ

• បន្តផ្តល់អាទិភាពវិភាជថវិកាដល់វិស័យអប់រំ និងសុខាភិបាលឱ្យស្របទៅតាមគោលដៅគោល-នយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

- បន្តផ្តល់អាទិភាពវិភាជថវិកាសម្រាប់ការអភិវឌ្ឍប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធរបវត្ត ការអភិវឌ្ឍកសិកម្ម និងការអភិវឌ្ឍជនបទ ស្របទៅតាមគោលដៅគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ពិសេសគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។
- បន្តផ្តល់មូលនិធិថវិកាឃុំ- សង្កាត់ឆ្នាំ២០១៣ ក្នុងកម្រិត២,៨០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិ ឆ្នាំ២០១២ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ហើយត្រូវបានគណនាស្មើនឹង០,៣២% នៃផសស។
- ចំពោះថវិកាថ្នាក់ក្រោមជាតិ ត្រូវបន្តអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងរាល់នីតិវិធីដែលមានជាធរមានស្របតាមមាត្រា៨៧ នៃអន្តរប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ទាំងថវិកាផ្ទាល់ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិ ក្នុងពេលដែលការរៀបចំក្របខ័ណ្ឌគតិយុត្តិសម្រាប់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល កំណត់ និងផ្ទេរមុខងារ ដើម្បីឈានទៅបង្កើតថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅពុំទាន់ចប់សព្វគ្រប់នៅឡើយ។
- បន្តផ្តល់អាទិភាពវិភាជថវិកាដល់ថវិកាកម្មវិធី និងផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានបញ្ជាក់ពីទិសដៅគោលនយោបាយ គោលបំណង កម្មវិធី និង/ឬយុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និងសូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងបង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ក្នុងគោលដៅបន្តពង្រឹង និងការកែលម្អការរៀបចំ និងការអនុវត្តថវិកាកម្មវិធី។

**ខ- __គម្រោងចំណូលថវិកា__**

១៩- ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃគម្រោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយ ចំណូល និងការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចឱ្យបាននូវកម្រិតចំណូលក្នុងស្រុកសរុបប្រមាណ ១៣,៩៤% នៃផសស គឺកើនឡើង០,៥១% នៃផសស និងមានកំណើនប្រមាណ១៤,៣% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសម្រេចឱ្យបាន១២,០២% នៃផសស គឺមានកំណើន០,៥៥% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន១,៦៨% នៃផសស គឺថយចុះ០,១៣% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។ ទន្ទឹមនឹងនេះ ចំណូលមូលធនក្នុងស្រុកត្រូវសម្រេចឱ្យបាន ០,២៤% នៃផសស គឺកើនឡើង៩២,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

២០- ដើម្បីសម្រេចបានតាមគោលដៅនៃការប្រមូលចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តជំរុញឱ្យកាន់តែសកម្មថែមទៀតក្នុងការអនុវត្តសកម្មភាពការងារ និងបណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតលើបណ្តាវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

**ទី១- ផ្នែកចំណូលពន្ធដារ**

- បន្តពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និងការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត។

- បន្តពង្រឹងការអនុវត្តកម្មវិធីកែលម្អរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ។

- បន្តបញ្ចប់ការកសាង និងចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា។

- បន្តពង្រឹងការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និងឱ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និងពង្រឹងការអនុវត្តរបបពិតនៅតាមបណ្តារាជធានី ខេត្ត និងបន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ។

- បន្តបណ្តុះបណ្តាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម។

- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និងឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និងឧស្ម័ន។

- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្ត និងលទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និងបណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។

**ទី២- ផ្នែកចំណូលពន្ធគយ និងរដ្ឋាករ**

- បន្តជំរុញការរៀបចំតាមការចាំបាច់នៃការងារនូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់គយ ពិសេសសម្រាប់បន្តកែលម្អបរិស្ថានធុរកិច្ច និងវិនិយោគ និងសម្រាប់រឹតបន្តឹងវិធានការបំបាត់អំពើរត់ពន្ធគយ។

- បន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ-ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុម-ហ៊ុននាំចេញ-ចូល និងក្រុមហ៊ុនដើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និងភាពងាយស្រួលក្នុងការត្រួតពិនិត្យ និងក្នុងការយកពន្ធ និងអាករផ្សេងៗ។

- បន្តរៀបចំកែលម្អនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

- បន្តជំរុញការអនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

*ក. បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ* ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរដែនដី។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពថែមទៀត ក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ ជាពិសេស លើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេទយិតភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារអេឡិចត្រូនិច និងការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី។

*ខ. បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន* រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និងកាតព្វកិច្ចពន្ធដារ។

*គ. បន្តរិះរក និងដាក់ឱ្យអនុវត្តនូវវិធានការច្បាស់លាស់ និងទន់ភ្លន់* លើមុខទំនិញមួយចំនួនដើម្បីរក្សាប្រភពចំណូល។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និងរដ្ឋាករមានជាអាទិ៍: បន្តការបណ្តុះ-បណ្តាល និងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និងសីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលគយឱ្យបានរឹងមាំ។

- បន្តពង្រឹង និងពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និងយន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលម្អប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលើកកំពស់គុណភាពសេវាកម្ម ជូនដល់អតិថិជន។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ទី៣- ផ្នែកចំណូលមិនមែនសារពើពន្ធ**

- បន្តជំរុញការដាក់ឱ្យអនុវត្តបង្កាន់ដៃជាតិសម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទនៅតាមគ្រប់ក្រសួង ស្ថាប័ន ក្នុងគោលដៅបង្កើនការគ្រប់គ្រង និងការប្រមូលចំណូល។

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ០២ បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេស បទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ពិសេស បន្តពង្រឹងការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីធានាឱ្យមានការបង់ចំណូលទាំងនេះចូលថវិការដ្ឋឱ្យបានទៀងទាត់ទាន់ពេលវេលា និងដោយគ្មានការកាត់ទុកសម្រាប់ចំណាយដោយប្រការណាមួយឡើយ។

- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍

និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និងចំណូលពីការជួលរោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូល។

- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើរការផ្តល់ និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យា សម្បទានគ្រប់ប្រភេទចូលថវិកាជាតិ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិនៃកម្ពុជា ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលនេះ។

២១- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសម្រាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចាប់ផ្តើមការចរចា និងពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ជាមួយក្រសួង ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្តទាំងអស់ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០១២។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១២ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១២ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឱ្យបានមុនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២។

## គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

២២- ពិតណាស់ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបាននិងកំពុងធ្វើឱ្យការគ្រប់គ្រងចំណូលនិងចំណាយកាន់តែល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែងត្រូវបានឆ្លុះបញ្ចាំងដោយកំណើនឡើងនៃភាពជឿទុកចិត្តលើថវិកា ដែលធ្វើឱ្យរាជរដ្ឋាភិបាលដោះស្រាយបំណុលចាស់បានទាំងស្រុង និងបញ្ឈប់បាននូវប្រពៃណីខ្វះសាច់ប្រាក់ទូទាត់ចំណាយ ហើយថែមទាំងដោះស្រាយបាននូវវិបត្តិសេដ្ឋកិច្ច និងវិបត្តិព្រំដែនក្នុងពេលថ្មីៗកន្លងទៅទៀតផង។ ទន្ទឹមនឹងបញ្ហាប្រឈមចំពោះមុខ ដែលត្រូវបន្តជំរុញការបង្កើនចំណូលពន្ធដារក្នុងស្រុកដើម្បីបំពេញនិន្នាការថយចុះនៃចំណូលពន្ធទាំចូល និងហានិភ័យនៃកត្តាខាងក្រៅដែលអាចជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច និងចំណូលជាយថាហេតុ រាជរដ្ឋាភិបាលត្រូវបន្តជំរុញការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធក្នុងការគ្រោង ការអនុវត្ត និងការគ្រប់គ្រងចំណូល និងចំណាយ ដើម្បី

អាចដោះស្រាយប្រកបដោយប្រសិទ្ធភាពទៅនឹងតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់។ ប្រការនេះទាមទារឱ្យរាជរដ្ឋាភិបាល ពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាសេនាធិការត្រូវតែបន្តជំរុញបន្ថែមទៀតនូវការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២នេះដើម្បីបន្តពង្រឹងភាពជឿទុកចិត្តលើថវិកាឱ្យកាន់តែរឹងមាំ បន្តបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឱ្យកាន់តែល្អប្រសើរ និងជាបណ្តើរៗបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមរយៈការផ្តោតលើការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

*ទី១-* ត្រូវបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឱ្យបានសមស្របព្រោះវាជាមូលដ្ឋានដ៏សំខាន់របស់ក្រសួង ស្ថាប័ន ក្នុងការគូសបញ្ជាក់អំពីគោលបំណងគោលនយោបាយរបស់ខ្លួនដើម្បីការពារ និងអះអាងលើតម្រូវការចំណាយរបស់ខ្លួន និងដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ត្រូវពង្រឹងការរៀបចំថវិកាឱ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រឹត ដើម្បីកាត់បន្ថយជាអតិបរមានូវចំណាយមិនបានគ្រោងទុក និងសំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និងចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយភាពជឿទុកចិត្តបាន គណនេយ្យភាព និងប្រសិទ្ធភាព។

*ទី២-* ត្រូវបន្តជំរុញការរៀបចំផែនការលទ្ធកម្ម និងកម្មវិធីចំណូល- ចំណាយឱ្យបានទាន់ពេលវេលាសុក្រឹត និងអនុវត្តឱ្យបានម៉ឺងម៉ាត់ ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ធានាបន្តពង្រឹងភាពជឿទុកចិត្តលើថវិកា បង្កើនគណនេយ្យភាព តម្លាភាពនិងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា។ ទន្ទឹមនឹងនេះ ត្រូវបន្តបង្កើនការគោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងវិន័យថវិកាទាំង១០។

*ទី៣-* ត្រូវបន្តពង្រឹងការគ្រប់គ្រងបំណុល ពិសេស ការអនុវត្តយុទ្ធសាស្ត្រ និងយន្តការគ្រប់គ្រងបំណុលរបស់រាជរដ្ឋាភិបាល ការកសាងទិន្នន័យ ការរៀបចំកម្មវិធីសងបំណុលឱ្យបានច្បាស់លាស់និងដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងថវិកាប្រចាំឆ្នាំ និងការបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការខ្ចីតែឥណទានសម្បទាន និងដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

*ទី៤-* ត្រូវបន្តត្រៀមលក្ខណៈ និងគ្រប់គ្រងឱ្យបានល្អនូវបណ្តាបញ្ហាប្រឈមថ្មី ឬជាយថាហេតុដូចជាសម្ពាធអតិផរណា ចំណាយសម្រាប់ដោះស្រាយគ្រោះធម្មជាតិ តម្រូវការចំណាយសម្រាប់ការការពារអធិបតេយ្យ និងបូរណភាពទឹកដី តម្រូវការចំណាយសម្រាប់ការងារបោះឆ្នោតរដ្ឋសភា ព្រមទាំងកាតព្វកិច្ចអន្តរជាតិ និងកិច្ចប្រជុំផ្សេងៗដែលចេះតែកើនឡើងជាលំដាប់។

## IV- នីតិវិធីនិងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០១៣

### ក- ការគ្រោងចំណូលថវិកាឆ្នាំ២០១៣

២៣- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុនដែលជាប្រភពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងបណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម÷
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ។
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ។
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ។
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យនិងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ។
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបានដោយសារការពង្រឹងនិងកែលម្អរដ្ឋបាល និងគោល-នយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធនិងការប្រមូលបំណុលពន្ធដែលត្រូវទារ ។
- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុនដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

**ខ- ការគ្រោងចំណាយថវិកាឆ្នាំ២០១៣**

២៤- ***ការរៀបចំគម្រោងឥណទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគណនាតម្រូវការថវិកាដោយលម្អិតទៅតាមជំពូក គណនី និងអនុគណនី និងដោយផ្អែកលើតម្រូវការចំណាយជាក់ស្តែង និងដោយផ្ទាល់សម្រាប់អនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពឬផ្នែកនីមួយៗចំណុះឱ្យក្រសួងស្ថាប័ននិងមន្ទីរជំនាញរាជធានីខេត្ត (តាមគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ) ដើម្បីបម្រើឱ្យកម្មវិធី/យុទ្ធសាស្ត្រអាទិភាពចាំបាច់របស់ក្រសួង ស្ថាប័នក្នុងការសម្រេចនូវគោលបំណងគោលនយោបាយរបស់ខ្លួន ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។*** រីឯការគណនាឥណទានចំណាយ ត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជាតារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតម្លៃសម្ភារៈនៃការផ្គត់ផ្គង់ និងត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬសេចក្តីណែនាំ ដូចជាចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយដំណើរការសាលាសម្រាប់សិស្ស ឬនិស្សិតម្នាក់ ឬត្រូវផ្អែកទៅតាមតួលេខ ស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសម្រាប់ការគ្រប់គ្រងកន្លងមក។ ជាពិសេសតម្រូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និងមានឯកសារគាំទ្រភ្ជាប់មកជាមួយដើម្បីពន្យល់ទៅតាមជំពូក គណនី និង អនុគណនីនីមួយៗ។

**គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ២០១៣**

២៥- រាជរដ្ឋាភិបាលបានធ្វើការកំណត់កញ្ចប់ថវិកា ដោយកំណត់ជាគោលការណ៍ចំណាយទៅតាមប្រភេទ និងជំពូក ដោយផ្អែកលើស្ថានភាព និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈសម្រាប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ធ្វើជាមូលដ្ឋានក្នុងការរៀបចំគម្រោងចំណាយលម្អិតទៅតាមគណនី និងអនុគណនី និងទៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព ឬផ្នែកនីមួយៗចំណុះឱ្យ

ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក្នុងការអនុវត្តសកម្មភាពការងារជាក់ស្តែង និងចាំបាច់របស់ខ្លួន ដើម្បីបម្រើឱ្យកម្មវិធី/យុទ្ធសាស្ត្រអាទិភាព និងដើម្បីសម្រេចបានតាមគោលដៅនៃគោលបំណងគោលនយោបាយរបស់ខ្លួន ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ***ដូចជាឆ្នាំមុនៗដែរ ការផ្ទេរនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវបានអនុញ្ញាតឱ្យធ្វើចាប់ពីត្រីមាសទី៣ គឺបន្ទាប់ពីការអនុវត្តបាន២ ត្រីមាស។***

២៦- ក្រសួង ស្ថាប័ននិងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងបណ្តាវិធានការដូចខាងក្រោម៖

**ក- ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)** ត្រូវគ្រោងដោយបង្កើន ២០% លើបៀវត្សមូលដ្ឋានទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១២ ។ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន និងមិនត្រូវគ្រោងទេ។ ចំពោះការឡើងឋានៈ និងកាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។ ក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មិនត្រូវគិតអតិថរណានៅក្នុងការគ្រោងចំណាយបៀវត្សនេះទេ។ ចំពោះបុគ្គលិកអណ្តែត និងភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ជ្រើសរើស និងប្រើប្រាស់ ។

**ខ- ចំណាយសម្រាប់ការទិញ និងសេវា (ជំពូក៦០ ៦១ និង៦២)** ត្រូវគ្រោងប្រកបដោយលក្ខណៈស្និតស្បៀត និងសន្សំសំចៃបំផុត ពិសេសលើមុខសញ្ញាទិញឧបករណ៍សម្ភារៈបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការជួសជុលធំ សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវ និងបេសកកម្មក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី និងទឹកជាដើម។ ការគ្រោងចំណាយឆ្នាំ២០១៣ សម្រាប់ជំពូកការទិញ និងសេវានេះ ត្រូវកំណត់ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។ ដូច្នេះ មានន័យថាក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវផ្អែកលើកញ្ចប់ឥណទានថវិកាឆ្នាំ២០១២ នៃជំពូកចំណាយសម្រាប់ការទិញ និងសេវា ហើយកាត់ចេញនូវមុខចំណាយដែលលែងត្រូវការ ឬ/និង មុខចំណាយដែលបម្រើឱ្យសកម្មភាពដែលត្រូវបានបញ្ចប់ រួចធ្វើការវិភាជឡើងវិញសម្រាប់សកម្មភាពថ្មី ឬ/និង ដើម្បីបង្កើនប្រសិទ្ធភាពចំណាយ។

**គ- ចំណាយសម្រាប់ការឧបត្ថម្ភធន និងជំនួយសង្គម (ជំពូក ៦៥)** ត្រូវគ្រោងទៅតាមតម្រូវការចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ចំពោះចំណាយដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវអនុវត្តដោយផ្ទាល់ ត្រូវគ្រោងទៅតាមគោលការណ៍ ឬ/និង កិច្ចសន្យា ដែលជាកាតព្វកិច្ចរបស់រដ្ឋ និងនៅជាធរមាន។ ការគ្រោងចំណាយឆ្នាំ២០១៣ សម្រាប់ជំពូកចំណាយឧបត្ថម្ភធន និងជំនួយសង្គមនេះ ត្រូវកំណត់ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុ

សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ទោះជាក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មានគោលនយោបាយ គោលការណ៍ ឬ/និងកិច្ចសន្យាថ្មីក៏ដោយ។ ដូច្នេះ មានន័យថាក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវផ្អែកលើកញ្ចប់ឥណទានថវិកាឆ្នាំ២០១២ នៃជំពូកចំណាយសម្រាប់ការឧបត្ថម្ភធន និងជំនួយសង្គម ហើយកាត់ចេញនូវមុខចំណាយដែលលែងត្រូវការ ឬ/និងមុខចំណាយដែលបម្រើឱ្យសកម្មភាពដែលត្រូវបានបញ្ចប់ រួចធ្វើការវិភាជឡើងវិញ សម្រាប់សកម្មភាពការងារដែលត្រូវបន្ត និងសម្រាប់គោលនយោបាយ ឬ/និងសកម្មភាពថ្មីប្រសិនបើមាន ឬ/និងដើម្បីបង្កើនប្រសិទ្ធភាពចំណាយ។ ក្នុងករណីមានគោលនយោបាយឬ/និងសកម្មភាពថ្មីដែលការវិភាជឡើងវិញពីកញ្ចប់ឥណទានថវិកាឆ្នាំ២០១២ មិនអាចគ្រប់គ្រាន់សម្រាប់បម្រើឱ្យគោលនយោបាយ ឬ/និងសកម្មភាពថ្មីនោះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ ត្រូវលើកគម្រោងចំណាយនោះដោយឡែក ពិសេសសម្រាប់អាជ្ញាធរ គណៈកម្មាធិការ ឧត្តមក្រុមប្រឹក្សា ក្រុមប្រឹក្សា និងគ្រឹស្ថានសាធារណៈរដ្ឋបាល ព្រមទាំងអង្គភាពដែលចំណុះឱ្យក្រសួង ស្ថាប័ន។ ដោយឡែកចំពោះចំណាយដែលត្រូវអនុវត្តដោយអង្គភាពស្វយ័ត ឬអង្គភាពដែលមានថវិកាដោយឡែក ត្រូវគ្រោងដោយផ្អែកលើគោលការណ៍តាមជំពូកដែលបានកំណត់នៅក្នុងចំណុច **ក** និង **ខ** ខាងលើ។ ចំពោះ ក្រសួង ស្ថាប័ន ដែលត្រូវបន្ត ឬចាប់ផ្តើមអនុវត្តសាកល្បងថវិកាកម្មវិធី ត្រូវរៀបចំគម្រោងចំណាយជាពីរផ្នែក សម្រាប់ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី ទៅតាមគ្រប់ជំពូក គណនី និងអនុគណនីនីមួយៗ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំងនេះ មកការពារគម្រោងថវិកាកម្មវិធីដោយឡែក។

**ឃ- ការគណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិកត្រូវផ្អែកលើមូលដ្ឋានពីរគឺ៖** ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោង និងប្រសិទ្ធភាពនៃចំណាយ ជាពិសេសដើម្បីមានមូលដ្ឋានច្បាស់លាស់សម្រាប់ធ្វើជាអំណះអំណាងនៃតម្រូវការថវិកា ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវធ្វើការគណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក (ជំពូក៦០ ៦១ ៦២ និង៦៥) ដោយផ្អែកលើមូលដ្ឋានពីរដូចខាងក្រោម៖

- ***កំណត់ចំណាយជាប្រចាំហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់*** ។ ចំណាយជាប្រចាំគឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយសម្ភារៈផ្គត់ផ្គង់ថែទាំជាប្រចាំ(ដូចជាសម្ភារៈផ្គត់ផ្គង់ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារៈផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជាសម្ភារៈការិយាល័យ ការបោះពុម្ព និងទិញឯកសារ សម្ភារៈបរិក្ខារ ប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋានសម្រាប់ក្រសួងស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើ អគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះគួរកំណត់ឱ្យច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំងវិភាជទៅតាមនាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។

- ***កំណត់ចំណាយមិនជាប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់។*** ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយ

បំពាក់ឧបករណ៍សម្ភារៈការិយាល័យ ឧបករណ៍សម្ភារៈដឹកជញ្ជូន សម្ភារៈបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារៈប្រើប្រាស់ផ្សេងៗដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះគួរកំណត់ឱ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ការចំណាយប្រភេទនេះសម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

**ង-** ឯកសារផែនការយុទ្ធសាស្ត្រថវិកា គម្រោងចំណូល និងគម្រោងចំណាយថវិកាឆ្នាំ២០១៣ ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាមូលដ្ឋានសម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិកាដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់ការប្រជុំការពារថវិកាទេនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះ ឱ្យបានទាន់ពេលវេលាដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃថវិកាឆ្នាំ២០១២ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើសម្រាប់កំណត់គម្រោងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការប្រជុំការពារថវិកា និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ឱ្យបានទាន់ពេលវេលា។

### ឃ-ការរៀបចំ និងការវិភាគសំណើនានា

**២៧-** ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (n-1) ឆ្នាំ២០១២ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២១១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ២០១៣ ឆ្នាំ (n) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និងការណែនាំទាំងឡាយខាងលើនេះសម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា៖
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្តមានការប្រែប្រួល ។
  - ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ។
- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និងចំណាយរដ្ឋបាល។ល។

២៨- គម្រោងថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបានលុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ។

២៩- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬមានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ។

៣០- បច្ចេកទេសវិភាគដទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និងអត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួនសម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តនីមួយៗ ត្រូវតែបម្រើទៅលើ៖

- ទិសដៅ និងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។
- កម្មវិធី និងយុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសម្រេចបាននូវគោលបំណង និងទិសដៅនៃគោលនយោបាយរបស់ខ្លួន។
- ផែនការសកម្មភាព និងរាល់មធ្យោបាយដំណើរការ ដើម្បីអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព។
- ការគ្រប់គ្រង ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសម្រាប់សម្រេចបានគោលបំណង និងទិសដៅនៃគោលនយោបាយរបស់ខ្លួន។

## V- សេចក្តីសន្និដ្ឋាន

៣១- ខ្លឹមសារនៃសារាចរណែនាំនេះ បានផ្តល់នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងគោលការណ៍ និងនីតិវិធីក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួនឱ្យឆ្លើយតបទៅនឹងកម្មវិធី យុទ្ធសាស្ត្រអាទិភាព ព្រមទាំងទិសដៅ និងគោលបំណងនៃគោលនយោបាយតាមវិស័យនិងតាមផ្នែករៀងៗខ្លួន សំដៅបម្រើឱ្យបានសម្រេចនូវគោលដៅ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** ក៏ដូចជាគោលដៅនៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យគឺ ការរក្សាកំណើនប្រកបដោយចីរភាពក្នុងរង្វង់ប្រមាណ៧% និងការកាត់បន្ថយភាពក្រីក្រឱ្យបានជាង១% ក្នុងមួយឆ្នាំៗ ព្រមទាំងការបន្តរក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុតក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ភាពសុខដុមរមនាសង្គម និងសុខុមាលភាពរបស់ប្រជាជន***។ ដូច្នេះ ដើម្បីឱ្យធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព

ខ្ពស់នោះ ទាមទារឱ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់មានទិសដៅ និងគោលបំណងនៃគោលនយោបាយរបស់ខ្លួនយ៉ាងច្បាស់លាស់ដែលផ្សារភ្ជាប់ទៅនឹង ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣*** មានកម្មវិធី និងយុទ្ធសាស្ត្រអាទិភាពជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវ ក្នុងការអនុវត្តឆ្ពោះទៅសម្រេចឱ្យបាននូវគោលបំណង និងទិសដៅនៃគោលនយោបាយរបស់ខ្លួន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ជាពិសេសការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៣២- ពេលទទួលសារាចរណែនាំនេះ ***គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ជំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២*** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាកម្រិតជំនាញ និងបូកសរុបសម្រាប់ការចរចាចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម០,1 លានរៀល។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា)។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១២*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"***ដើម្បីជូនជ្រាប***"

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី ខេត្ត

"***ដើម្បីអនុវត្ត***"

- ឯកសារ-កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៤១៤ ឧស៤-គ.ក-ប្រក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៨៨៨ /១២ គ.វ.ក ចុះថ្ងៃទី១៣.០៣.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ឥណ្ឌូចិន ហ្គាវ័ន្ត (ខេមបូឌា) ចុះថ្ងៃទី២៩.០២.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ឥណ្ឌូចិន ហ្គាវ័ន្ត (ខេមបូឌា) (INDOCHINE GAWON (CAMBODIA).,LTD.) តំណាងដោយ លោកស្រី CHA KYEONGHEE សញ្ជាតិកូរ៉េ អាយុ៤៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M68141357 ចុះថ្ងៃទី១៩.០៣.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ 233-23, Dongdaemun-Gu, Seoul, Korea. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

- **ឈ្មោះផលិតផល** **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
  សម្លៀកបំពាក់ ១៤១០



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

- **ផ្លាកឈ្មោះរោងចក្រ ៖** " *រោងចក្រកាត់ដេរសម្លៀកបំពាក់ ឥណ្ឌូចិនហ្គាវ៉េន្ត (ខេមបូឌា)* "
- **ទីតាំងរោងចក្រ ៖** " *ភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។ ៗល៕

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៤១៦ ឧស្ស.ករ-ប្រក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ២៥៥៨ /១១ គ.រ.ក ចុះថ្ងៃទី០៣.១១.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ដាប់បែលយូ.អ៊ី.ជី.ស៊ី មេនូហ្វេកធីរីង លីមីធីត ចុះថ្ងៃទី១៨.១០.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ដាប់បែលយូ.អ៊ី.ជី.ស៊ី មេនូហ្វេកធីរីង លីមីធីត (W.E.G.C MANUFACTURING LIMITED.) តំណាងដោយ លោក ERIC, MARIE THIBAUT TAVERNIER សញ្ជាតិបារាំង អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 11AP39323 ចុះថ្ងៃទី ២៨.០៣.២០១១ មានអាសយដ្ឋានបច្ចុប្បន្ន៖ Vessel 32466 Royal Hong Kong, Yacht Club, Hebe Havven, Sai Kung, Hong Kong, China ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រលើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-កាបូប | ១៥១២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣

២-ស្រោមដៃកីឡា ៣២៣០

៣-មួកកីឡា ៣២៣០

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រផលិត កាបូបស្ពាយ កាបូបយួរ និងថង់ដាប់ប៊ែលយូ.អ៊ី.ជី.ស៊ី មេនូហ្វេកធើរីង លីមីធីត "*

**ទីតាំងរោងចក្រ ៖** *" មណ្ឌល១ សង្កាត់លេខ១ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រី

ស៊ុយ_សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តព្រះសីហនុ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ...................

រាជធានីភ្នំពេញ, ថ្ងៃទី.......ខែ.......ឆ្នាំ២០១...

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ២៧៦/១២ គ.រ.ក ចុះថ្ងៃទី១៣.០២.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន រ៉ាយស៍ មីល ខមផ្លេកស៍ ចុះថ្ងៃទី៣០.១២.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន រ៉ាយស៍ មីល ខមផ្លេកស៍ ( RICE MILL COMPLEX CO.,LTD. ) តំណាងដោយ លោក WICHAI ONGRATANAPHOL សញ្ជាតិថៃ អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ W792466 ចុះថ្ងៃទី២២.១០.២០០៨ មានទីលំនៅបច្ចុប្បន្ន៖ 115 Preeda View Building Soi.53 Rama 3 Rd., Bangpongpang, Yannawa, Bangkok Thailand. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដកំណត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| អង្ករ | ១០៦១ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855 23 211141 , Fax : 855 23 428263

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រកិនស្រូវ វ៉ាយស៍ មីល ខមផ្លេកស៍"*

**ទីតាំងរោងចក្រ៖** *"ភូមិភ្នំធំថ្មី ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តបន្ទាយមានជ័យ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តបន្ទាយមានជ័យ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ៤១៣៧ ឧរក.ចក ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៣ខែមករាឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

